# ជីវប្រវត្តិ

# នៃ

# ភិក្ខុវជិរប្បញ្ញោ សាន សុជា

## សេចក្តីបញ្ជាក់

ជាបឋម ខ្ញុំសូមជម្រាបពុទ្ធបរិស័ទថា ជីវប្រវត្តិនេះ **សុជាខ្ញុំ** រៀបចំសរសេរឡើងដោយផ្ទាល់ដៃខ្លួនឯង ។ ជាធម្មតា ជីវប្រវត្តិនៃបុគ្គលម្នាក់ ៗ តែងត្រូវបានសរសេររៀបរាប់ដោយបុគ្គលដទៃ ជំនួសសាមីជីវិត ។ អ្នកសរសេរច្រើនតែនិយាយសរសើរ ឬអួតជំនួសម្ចាស់ជីវិត ។ ការនេះ ព្រោះហេតុអ្វី? ព្រោះអ្នកសរសេរ ពុំបានដឹងចិត្ត ឬបំណងរបស់សាមីជីវិតច្បាស់លាស់ផង ចង់លើកតម្កើងនូវតម្លៃនៃជីវិតរបស់បុគ្គលដែលខ្លួនសរសេរផង ។ មូលហេតុនេះហើយដែលនាំឲ្យជីវប្រវត្តិ ខុសឃ្លាតចាកសេចក្តីពិតយ៉ាងច្រើន ។

**សុជាខ្ញុំ** មិនមែនជាអ្នកប្រាជ្ញ និងមិនមែនជាមនុស្សអស្ចារ្យដែលគេមិនអាចបំភ្លេចបាន ក្រោយពេលដែលលាចាកលោកនោះទេ ប៉ុន្តែដោយមិនចង់ឲ្យជីវប្រវត្តិរបស់ខ្លួន ពោរពេញដោយភាពអំនួត

ឬមិនត្រឹមត្រូវតាមសេចក្តីពិត ទើបឆ្លៀតឱកាសដែលខ្លួនកំពុងមានជីវិតនៅឡើយ សរសេរជីវប្រវត្តិនេះឡើង ។ ការសរសេរនេះពុំមែនមានន័យថា **សុជាខ្ញុំ**ចង់អួតពីជីវិតខ្លួនឯងទេ គឺមានន័យថា ខ្ញុំគោរពសច្ចធម៌ និងគោរពគណៈសិស្សគ្រប់គ្នា ។ និយាយបែបនេះហាក់ដូចជាខ្ញុំបានដឹងច្បាស់ថា ខ្លួនឯងត្រូវស្លាប់ពេលណាអ៊ីចឹង ។ តាមពិតខ្ញុំមិនដឹងទេ គ្រាន់តែដឹងតាមព្រះពុទ្ធដីកាថា "ជីវិតមិនទៀងតែសេចក្តីស្លាប់ទៀង" ។ **សុជាខ្ញុំ** ធ្លាប់មានអាពាធធ្ងន់ស្ទើរតែដាច់ជីវិតច្រើនលើកច្រើនគ្រាមកហើយ បើមិនសរសេរទុកឲ្យហើយពិតជាហួសពេល, ដើម្បីកុំឲ្យគេយករឿងមិនពិតទៅសូធ្យកូតករនៅមុខឈាបនដ្ឋានច្រើនពេក ។

ក្រោយពេលដែលសរសេររួច បើបុណ្យអនុគ្រោះឲ្យជីវិតខ្ញុំរស់បានច្រើនឆ្នាំតទៅទៀត ខ្ញុំក៏មិនចាំបាច់ចំណាយពេលវេលាឆ្លើយតបសំនួររបស់ពុទ្ធបរិស័ទដោយច្រើន ដែលតែងតែចង់ដឹងពីប្រវត្តិរបស់ខ្ញុំដែរ ហើយប្រវត្តិដែលបានចារទុកក្នុងសំនេរនេះ មានសេចក្តីពិស្តារជាងការដែលខ្ញុំឆ្លើយផ្ទាល់មាត់ ។ សេចក្តីដូចបានបំភ្លឺមកនេះសូមមិត្តអ្នកអានជ្រាប ។

# ថ្ងៃកំណើត

*ខ្ញុំ **សាន សុជា** កើតនៅថ្ងៃអង្គារ ៧ រោច ខែ មិគសិរ ឆ្នាំ ម្សាញ់ ព.ស. ២៥២០ ចុង គ.ស. ១៩៧៦ នៅទួលតាអុក ឃុំកំពង់ឃោល ស្រុកទ្រាំង ខេត្តតាកែវ ក្នុងរបបកម្ពុជាប្រជា-ធិបតេយ្យរបស់លោក **ប៉ុល ពត**, ជាកូនរបស់លោកឪពុក **ទឹម ទុយ** និងអ្នកម្ដាយ **អៀង ចែម** សព្វថ្ងៃទីនោះស្ថិតនៅក្នុង ឃុំគោកពោធិ៍ ស្រុកបូរីជលសា ខេត្តជដែល ។ សម័យនោះ គ្រួសារនេះស្ថិតនៅក្នុងពួក**អ្នកត្រៀម** និងពួក**អ្នកផ្ញើ** ហៅថា ១៧ ដោយមិនមានសមាជិកណាម្នាក់នៃគ្រួសារនេះ បានជាអ្នកពេញ សិទ្ធិទេ ហើយមានការទទួលរងទុក្ខមិនខុសពីប្រជាជនទូទៅ ដែរ ។ **សុជាខ្ញុំ** បានកើតនៅក្នុងសង្គមមួយដ៏ខ្មៅងងឹត ឥតមាន មន្ទីរពេទ្យ ឥតមានថ្នាំសង្កូវត្រឹមត្រូវឡើយ ។*

*បានឮមកថា ក្នុងសម័យនោះ ដោយខ្លាចប្រជាជនចូលដៃ ជាមួយពួកយួន **កម្មាភិបាលប៉ុល ពត** បានបំភ័យប្រជាជនថា "ពួកយួនឡើងមកវះពោះញាត់ស្មៅ អ្នកត្រូវតែរត់ទៅខាងលើ..." ប្រជាជនក៏បានភៀសខ្លួនចេញពីភូមិអស់ ។ គ្រួសារនេះក៏មាន បំណងរត់ទៅនឹងគេដែរ ។ ថ្ងៃនោះអ្នកម្ដាយចាប់ផ្ដើមឈឺផ្ទៃ លោកឪពុកបានគ្រាហ៍អ្នកម្ដាយឡើងលើរទេះ បរចេញពីភូមិ*

អ្នកតាត្បាល់ បានចម្ងាយជាងមួយគីឡូម៉ែត្រ អ្នកម្ដាយឈឺពោះ
កាន់តែខ្លាំង មិនអាចធ្វើដំណើរទៅទៀតបាន ក៏ចូលទៅសម្រាក
ក្នុងខ្ទមកម្សត់មួយ នៅឯការដ្ឋានទួលតាអុក ។ ភ្លាមនោះ **សុជាខ្ញុំ**
ក៏បានប្រសូតចាកផ្ទៃម្ដាយ នៅវេលាម៉ោង ១២ ថ្ងៃត្រង់ ។ លោក
ឪពុកបានយកកង់ជិះយ៉ាងលឿនទៅអង្វរលោកយាយ**ធ្លក** ជាធ្មប
ដែលបានភៀសខ្លួនទៅឆ្ងាយហើយ លោកឪពុកទៅទាន់យាយហ្លួប
នៅខាងលិចវត្តគោកពោធិ៍ ។ ពេលនោះ លោកយាយ**ធ្លក**ប្រកែក
មិនហ៊ានត្រឡប់មកជួយទេ ព្រោះខ្លាចយួនវះពោះញាត់ស្មៅ ។
លោកឪពុកចុះកាន់កង់បណ្ដើរអង្វរលោកយាយហ្លួប ដោយពាក្យ
ជាដើមថា “ឲ្យតែលោកយាយទៅជួយកាត់ទងផ្ចិតកូនខ្ញុំរួច ខ្ញុំនឹង
ឌុបលោកយាយត្រឡប់មកឲ្យទាន់គេវិញ.....” អស់រយៈចម្ងាយ
ប្រហែលជិតកន្លះគីឡូម៉ែត្រ ទើបលោកយាយហ្លួបព្រម ។
ទម្រាំតែលោកឪពុកឌុបធ្មបមកដល់ **សុជាខ្ញុំ**បានដេកយំនៅលើ
រនាបឫស្សី អស់រយៈពេលជិតពីរម៉ោងទៅហើយ តាំងពីយំឮ
រហូតដល់យំលែងឮ ឯខ្លួនក៏ស្វិតអស់ សាច់ក្បាលរលាត់ចេញ
ឈាម ដោយកកិតនឹងរនាបឫស្សី និងក្បាលដែកគោល ។
លោកយាយហ្លួបបានចាត់ការតាមវិធីធ្មបបុរាណ រួចស្រេចកាល
ណា លោកឪពុកក៏ឌុបយាយហ្លួបត្រឡប់ទៅកន្លែងដើម ។

*ឯជំណាំងថា យួនឡើងមកវះពោះនោះ ជាជំណាំងក្លែងក្លាយ អស់រយៈពេល ពីរបីថ្ងៃ ប្រជាជនក៏បានត្រឡប់មកវិញ ហើយធ្វើការងារតាមការបញ្ជារបស់កម្មាភិបាល* ***ប៉ុល ពត*** *ដូចដើមវិញ ។ ចំពោះសេចក្តីទុក្ខនៃគ្រួសារនេះ ខ្ញុំមិនចាំបាច់រៀបរាប់ទេ ព្រោះប្រជាជនស្ទើរតែទាំងអស់ ក្រៅពីកម្មាភិបាល* ***ប៉ុល ពត*** *សុទ្ធតែជួបប្រទះដូចគ្នា ។*

## គ្រួសារសុខារក្រោយថ្ងៃរំដោះ

*ក្រោយថ្ងៃរំដោះ គ្រួសារនេះ បានត្រឡប់ទៅសាងគេហដ្ឋាននៅភូមិអ្នកតាត្បាល់វិញ និងចាប់ផ្តើមធ្វើកសិកម្ម និងនេសាទកម្មដូចគ្រួសារដទៃដែរ ប៉ុន្តែជីវភាពគ្រួសារមិនរីកចម្រើនទេ ។ ខ្ញុំចាំបានថាធ្លាប់បានបរិភោគបាយដាំលាយជាមួយនឹងពោតក្រហម ដែលលោកឪពុកយកស្ករទៅដូរនៅឯស្រុកកោះធំ ខេត្តកណ្តាល ។*

| | |
|---|---|
| រឿងរ៉ាវជីវិតមិនពិតប្រាកដ | មិនអាចកំណត់ដោយខ្លួនឯងបាន |
| គ្រប់គ្នាសុទ្ធតែចង់រុងរឿងថ្កាន | តែមិនអាចបានតាមប្រាថ្នាឡើយ ។ |
| ជួនលិចជួនឡើងតាមតែវាសនា | ដែលកម្មបានចាររួចស្រេចមកហើយ |
| ត្រូវតែទទួលគេចមិនរួចឡើយ | តែដល់ពេលហើយគ្មានអ្នកជួយបាន ។ |
| បើចង់កែប្រែខ្សែរឿងជីវិត | ត្រូវមានគំនិតកុំភ្លឹកភ្លេចប្រាណ |
| ត្រូវខំសូត្ររៀនសាងកម្មកល្យាណ | ប្រាកដជាបានអនាគតរុងរឿង ។ |


កុមារា សាន សុជា

# ការសិក្សាពីកុមារវ័យ

**សុជាខ្ញុំ** អាយុ ៧ ឆ្នាំបានចូលរៀនថ្នាក់ដំបូងនៅសាលាបឋមសិក្សាវត្តពោធិមន្ត្រី ដែលនៅជិតភូមិ ។ មួយឆ្នាំបន្ទាប់ **សុជាខ្ញុំ**ត្រូវបានអ្នកគ្រូជ្រើសឲ្យឡើងទៅថ្នាក់ទី ១ ហើយលោកគ្រូនាយក និងគ្រូប្រចាំថ្នាក់ស្រឡាញ់រាប់អានណាស់ ព្រោះខ្ញុំរៀនបានពិន្ទុល្អ ចាត់ទុកថាជាសិស្សឆ្លាតគ្រាន់បើ ប៉ុន្តែបានពាក់កណ្តាលឆ្នាំ ស្ថានភាពគ្រួសារធ្វើឲ្យការសិក្សារបស់ខ្ញុំមិនរីកចម្រើនសោះ ។ ខ្ញុំចាំបានថា កាលនោះគ្រួសារ**សុជាខ្ញុំ**នៅសល់តែគោមួយក្បាលគត់ លោកឪពុកក៏សម្រេចចិត្តលក់គោនោះ ទៅទិញកូនទាចំនួនប្រាំរយក្បាលមកចិញ្ចឹម តាំងពីពេលនោះមក **សុជាខ្ញុំ**ក៏ក្លាយជាមនុស្សសកម្មម្នាក់ក្នុងគ្រួសារ គឺក្លាយជាអ្នកឃ្វាលទា ដោយក្រោកឡើងតាំងពីម៉ោង ៤ ព្រឹកទៅអូសកំពឹសនិងកូនត្រីឲ្យទាស៊ី សូម្បីតែខែរងាញ័រថ្គាមក៏ត្រូវតែធ្វើដែរ លុះម៉ោងប្រហែល ៧ ព្រឹក ក៏បណ្តើរកូនទាកាត់តាមវាលស្រែឲ្យចាប់ចំណី ។ ក្រោយរដូវប្រូតកាត់ **សុជាខ្ញុំ**ពុំសូវបានដេកនៅផ្ទះទេ លោកឪពុកបានយកទ្រុងទា ទៅធ្វើនៅកន្លែងណាដែលគេទើបតែប្រូតរួចដើម្បីខ្ញុំបណ្តើរទាឲ្យរើសគ្រាប់ស្រូវដែលធ្លាក់ក្នុងស្រែស៊ី ហើយពេលយប់ត្រូវដេកក្នុងរោងទានោះឯង ឯរោងទាត្រូវផ្លាស់ពីកន្លែង

មួយទៅកន្លែងមួយជាញឹកញាប់.......... ម្ល៉ោះហើយការសិក្សារបស់ខ្ញុំកាន់តែធ្លាក់ទៅ ៗ ព្រោះក្នុងមួយឆ្នាំ ៗ ខ្ញុំចូលរៀនបានតែពីរ ឬ បីខែប៉ុណ្ណោះ គឺពេលចូលកងបានប្រហែលជាងមួយខែ និងមុនឡើងថ្នាក់ប្រហែលជាងមួយខែ ប៉ុន្តែដោយឃើញថា**សុជាខ្ញុំ** ថ្វីដ្បិតតែមិនឈ្នះគេក្នុងចំណោមសិស្សពូកែ តែក៏អាចរៀនប្រហាក់ប្រហែលនឹងអ្នកមធ្យម ម្ល៉ោះហើយ លោកគ្រូអ្នកគ្រូនៅតែឲ្យខ្ញុំឡើងថ្នាក់រហូតថែមទាំងឲ្យខ្ញុំឡើងផ្លោះពីថ្នាក់ទី៣ ទៅថ្នាក់ទី៥ ដោយមិនបានរៀនថ្នាក់ទី ៤ ទេ ។ ការដែលខ្ញុំឈប់ច្រើននៅតែរៀនទាន់គេ ព្រោះពេលឈប់ខ្ញុំខំរៀនដោយខ្លួនឯង ត្រង់ណាដែលមិនយល់ខ្ញុំតែងទៅសាកសួរអ្នកជិតខាងដែលគេរៀនបានច្រើន ។ ពេលដែលខ្ញុំមិនបានទៅរៀនអស់កាលយូរថ្ងៃ ខ្ញុំតែងតែបានទទួលសំបុត្រពីគ្រូប្រចាំថ្នាក់ ដែលសរសេរមកលួងលោមឲ្យខ្ញុំត្រឡប់ទៅរៀនវិញ ជួនកាល**សុជាខ្ញុំ**អានសំបុត្រទាំងស្រក់ទឹកភ្នែក ដោយអរគុណលោកគ្រូអ្នកគ្រូណាស់ដែលមិនបញ្ឈប់ការសិក្សារបស់ខ្ញុំ ហើយតែងតែលើកទឹកចិត្តជានិច្ចតែមិនដឹងឆ្លើយតបទៅវិញដោយរបៀបណា នឹកកម្សត់តែម្នាក់ឯងចង់ទៅរៀនវិញ តែលៃមិនកើត ព្រោះគ្មានអ្នកជំនួស ម្យ៉ាងទៀតលោកឪពុកជាប់រវល់ធ្វើនេសាទកម្មនិងកសិកម្ម បងប្រុសត្រូវទៅរៀននៅ

អនុវិទ្យាល័យ ឯប្អូន ៗ សុទ្ធតែស្រី ។ ដោយសារការរៀនរំលង ថ្នាក់ផង ដោយការឈប់ច្រើនពេកផង ទោះបីខ្ញុំរៀនខ្លួនឯង យ៉ាងណា ក៏ខ្ញុំដឹងខ្លួនឯងថា ខ្ញុំរៀនមិនទាន់គេទេ កាលនោះខ្ញុំបាន ចំណាត់ថ្នាក់លេខ ១៧ ក្នុងចំណោមសិស្សប្រហែល ១៨ នាក់ ។ លុះចុងឆ្នាំ ខ្ញុំក៏បានចុះឈ្មោះប្រលងចូលអនុវិទ្យាល័យ លទ្ធផលគឺ "**ធ្លាក់**" ។ ក្នុងឆ្នាំនោះដែរ រដ្ឋបានបញ្ជូនលោកឪពុកទៅ ក៥ ឯអ្នកម្ដាយក៏លក់ទាចោល រួចទិញគោវិញ ។ ចាប់ពីពេលនោះមក **សុជាខ្ញុំ**មានពេល វេលាគ្រប់គ្រាន់ដើម្បីសិក្សា ។ ខ្ញុំធ្លាប់សន្យា នឹងប្អូនស្រីខ្ញុំថា "បើរៀនមិនបានលេខ ១ នឹងកាត់ម្រាមដៃឲ្យក្ដៅស៊ី" ដូចបំណងមែន ឆមាសទី ១ បានលេខ ២ ឆមាសទី ២ បានលេខ ១ ពេលទៅប្រលងចូលអនុវិទ្យាល័យក៏ជាប់ទៀត ។ អ្វី ៗ មិនដូច បំណងទេ បានម្យ៉ាងខ្វះម្យ៉ាង **សុជាខ្ញុំ**ប្ដីជ្បិតតែអាយុ ១៤ ឆ្នាំហើយ តែមាឪល្អិតជ្បិតឈឺច្រើន ធាក់កង់ទៅរៀនមិនរួច ព្រោះផ្លូវឆ្ងាយកាត់ វាលស្រែ រីឯខែទឹកជន់ក៏លំបាកឆ្លង ម្ល៉ោះហើយលោកឪពុកអ្នកម្ដាយ បានឲ្យខ្ញុំទៅស្នាក់នៅ ជាមួយអ៊ុំស្រីជីដូនមួយឈ្មោះ **អៀង សុផល** ហៅ **អ៊ាប** នៅភូមិ អង្កាញ់ ដែលមានទីតាំងមិនឆ្ងាយប៉ុន្មាន ពីសាលាអនុវិទ្យាល័យដូងខ្ពស់ ។ ខ្ញុំស្នាក់នៅទីនោះប្រហែល

ពីបីទៅបួនខែ ដល់រដូវសម្រកក៏លាអ៊ុំស្រីទៅផ្ទះវិញ ទ្រាំជិះកង់ទៅរៀនទាំងត្រជាក់ត្រជួស ។

# វិស័យសិល្បៈ

អំណោយពីធម្មជាតិ **សុជាខ្ញុំ**មានសម្លេងពីរោះគ្រាន់បើដែរ អាចច្រៀងបំពេរចាស់ ៗ ក្នុងភូមិឲ្យត្រជាក់ចិត្តបាន ប៉ុន្តែការនេះទាល់តែមានរង្វាន់ទើបច្រៀង មិនចេះតែច្រៀងឲ្យស្តាប់ដោយទទេ ៗ ឬច្រៀងរឡូរឡាដើម្បីសប្បាយឡើយ ។ **សុជាខ្ញុំ**ចេះច្រៀងតាំងពីមិនទាន់ចេះស្លៀកខោម៉្លេះ ក្រោយមកខ្ញុំរៀនច្រៀងតាមលោក **កែវ សារ៉ាត់** អ្នកស្រុកស្តាប់ហើយពោលសរសើរថា ដូច **កែវ សារ៉ាត់** បេះបិទ តាំងពីពេលនោះមក អ្នកស្រុកហៅ**សុជាខ្ញុំ**ថា **សារ៉ាត់ក្មេង** ហើយក្លាយជាអ្នកចម្រៀងប្រចាំសាលាតាំងពីបឋមសិក្សាមកម៉្លេះ ។ ក្រៅពីច្រៀង ខ្ញុំអាចហួចបានគ្រប់បទ ហើយការហួចទៀតសោត ខ្ញុំហួចមិនឲ្យដាច់សម្លេងទេ គឺហួចទាល់តែចប់បទមួយ ៗ ទើបឈប់ ដោយប្រើទាំងខ្យល់ចេញនិងខ្យល់ចូល អ្នកស្រុកស្តាប់ទៅ ឮហាក់ដូចជាខ្ញុំមិនដកដង្ហើមអ៊ីចឹង លើសពីនេះ ខ្ញុំអាចហួចធ្វើជាសម្លេងខ្លុយបាន ព្រោះហេតុនោះ ចាស់ ៗ ហៅខ្ញុំថា **កុមារខ្លុយទិព្វ** ។

ផ្នែកបទភ្លេងវិញ **សុជាខ្ញុំ**មិនធ្លាប់បានរៀនពីគ្រូណាទេ ប៉ុន្តែបើខ្ញុំមានឱកាសកាន់ឧបករណ៍ភ្លេងបានប្រហែលមួយម៉ោង ខ្ញុំអាចដេញត្រូវបានមួយបទឬពីរបទភ្លាម ព្រោះខ្ញុំចេះធ្វើបទភ្លេងតាមមាត់ ហើយរាវរកសម្លេងភ្លេងតាមសូរមាត់ខ្ញុំនោះឯង ។ ផ្នែកចម្លាក់និងគំនូរ ខ្ញុំមិនជាចេះណាស់ណាទេ ប៉ុន្តែបើក្នុងចំណោមនោះ មិនមានអ្នកចេះ ខ្ញុំក៏អាចធ្វើបាន តួយ៉ាងដូចជាបទុមចេតិយដែលកំពុងកសាង **សុជាខ្ញុំ**ជាអ្នកគូរឲ្យចេញជារូបរាងដំបូង ។ម្យ៉ាងទៀត ក្នុងនាមខ្ញុំជាកូនអ្នកស្រែ សិល្បៈធ្វើស្រែចម្ការដូចជា ភ្ជួរ រាស់ សាបព្រោះ ដកស្ទូង ច្រូតកាត់ បោកបែនជាដើម **សុជាខ្ញុំ**ចេះយ៉ាងស្ទាត់ និងធ្លាប់ប្រព្រឹត្តធ្វើយ៉ាងសកម្ម ។

# ផ្នែកសុខភាព

**សុជាខ្ញុំ** បើនិយាយពីសុខភាព ហាក់បីដូចជាចម្លែកណាស់ បើប្រៀបទៅនឹងមនុស្សធម្មតា ព្រោះអ្នកម្ដាយដំណាលប្រាប់ថា កាលខ្ញុំអាយុបាន ៦ ខែ មានរឿងអស្ចារ្យមួយកើតឡើង រឿងនោះគឺ "ថ្ងៃមួយ វេលាម៉ោង ១២ ថ្ងៃត្រង់ នៅឯរោងការដ្ឋាន ម្ដាយមីងខ្ញុំឈ្មោះ **អៀង ម៉ៅ** បានឃើញពស់ព្រៃមួយក្បាលនៅក្នុងប្រមូរកន្ទេល គាត់ក៏

វាយសម្លាប់ពស់ព្រៃនោះ រួចយកទៅបោះចោលនៅខាងត្បូងរោង ។ លុះអ្នកម្ដាយមកពីធ្វើការ អ្នកមីងបាននាំអ្នកម្ដាយទៅមើលពស់ដែលងាប់ហើយ ឃើញថាពស់នោះលៀនអណ្ដាតចេញមកក្រៅ និងមានឈាមហូរចេញតាមច្រមុះនិងមាត់ជាច្រើន ។ យប់នោះ **សុជាខ្ញុំ** ចាប់ផ្ដើមតឹងពោះ ប្រកាច់សន្ធប់ឈឹង លៀតអណ្ដាត និងមានឈាមហូរចេញតាមច្រមុះនិងមាត់ មានអាការដូចជាពស់ដែលអ្នកម្ដាយបានឃើញពីថ្ងៃ ។ យប់នោះ **សុជាខ្ញុំ**ប្រកាច់របៀបនេះ ៣ ដង លោកឪពុកអ្នកម្ដាយមិនបានសម្រាន្តទេ” ។ ចាប់ពីពេលនោះមក ខ្ញុំមានជម្ងឺបែបនេះជារៀងរហូត គ្រាន់តែមានការរង្វើលជាងមុន ជួនកាលមួយថ្ងៃ ២ ដង មួយថ្ងៃម្ដង ពីរថ្ងៃម្ដង បីថ្ងៃម្ដង មួយអាទិត្យម្ដង កន្លះខែម្ដង គឺថយជាលំដាប់ រហូតដល់អាយុ ១២ ឆ្នាំទើបជម្ងឺនោះបានជាសះស្បើយ ។ សុជាខ្ញុំធ្លាប់ឮចាស់ ៗ ហៅសួរ ថា “អាអូនអ្ហើយ! តើបានយើង ឬបានគេ ចៅ? ” ពាក្យនេះ គឺគេប្រើសម្រាប់អ្នកឈឺច្រើន អ្នកស្រុកខ្លះថាខ្ញុំជាមនុស្សឆ្កួតជ្រូក ខ្លះគិតថា **សុជាខ្ញុំ**ប្រហែលជាក្លាយជាមនុស្សល្ងីល្ងើមិនដឹងអី ព្រោះពេលនោះ ខ្ញុំសន្ធប់ញឹកញាប់ពេក ធ្វើឲ្យការចងចាំមិនពូកែ គឺតែងតែភ្លេចភ្លាំងដោយច្រើន ជួនកាលពាក្យខ្លះកំពុងតែ

និយាយទីផមាត់ក៏ភ្លេចបាត់ដែរ ។ កាលពីមុន **សុជាខ្ញុំ** មានឈ្មោះថា **សាន សារី** ជួនទីផបងប្រុសខ្ញុំ **សាន សារុន** ប៉ុន្តែដោយឈឺច្រើន បែបនេះ ទើបប្រែក្លាយឈ្មោះថា **សាន សុខជា** ។ ក្រោយពេលបួស លោកគ្រូខ្ញុំបានកែថា **សាន សុជា** ដូច្នេះវិញ ។

## ផ្នែករបួសស្លាម

**សុជាខ្ញុំ** មានគ្រោះថ្នាក់ផ្នែកក្បាលបីដង មាត់និងធ្មេញម្តង ពោះម្តង ។ ផ្នែកក្បាលនោះគឺ :

លើកទី ១ កាលមិនទាន់ដឹងក្តី រត់ប្រណាំងជាមួយបងប្រុស ទៅរកអ្នកម្តាយនៅឯចង្ក្រាន ដួលបោកនឹងជ្រុញ បែកត្រង់រង្វើល ក្បាលចំពីខាងលើ, រឿងនេះខ្ញុំមិនចាំទេ ។

លើកទី ២ អាយុប្រហែល ៧ ឆ្នាំ នៅចាំបានថា រសៀលថ្ងៃ មួយ ខ្ញុំបានហូបបាយកកនៅឯចង្ក្រាន ពាងលើផ្ទះអស់ទឹក ខ្ញុំក៏ចុះទៅ ផឹកទឹកក្នុងពាងខាងមុខផ្ទះ ។ គ្រាន់តែដាក់ជើងចុះស្រាប់តែរបូតដៃធ្លាក់ ក្បាលទៅមុនបោកនឹងជ្រុញទ្រាប់ជើងទំហំប្រហែលពីរចំអាម ៤ ជ្រុង ត្រូវចំក្បាលខាងស្តាំ ដែលមើលឃើញស្នាមរហូតសព្វថ្ងៃនេះ ។ ដោយត្រូវខ្លាំងពេក មិនឈឺទេ ទៅជាស្ពឹកអស់ ខ្ញុំខំក្រោកឈរឡើង

ស្រាប់តែមានអារម្មណ៍ថាមានទឹកក្តៅ ៗ ហូរស្រោចលើខ្លួន តាមពិតទឹកនោះគឺជាឈាមដែលហូរចេញពីក្បាលខ្លួនឯង ។ ដោយខ្លាចលោកឪពុកបន្ទោស និងភាពល្ងង់ខ្លៅ ខ្ញុំក៏ប្រញាប់ជូតទឹកងូតជម្រះឈាមនោះចេញ តែទឹកនោះប្រែពណ៌ទៅជាក្រហមទាំងអស់ ។ មើលទៅឃើញថាឈាមរឹតតែច្រើន ឯកម្លាំងរឹតតែថយ **សុជា**ខ្ញុំក៏ខំវារឡើងតាមជណ្តើរផ្ទះខាងមុខទៅរកលោកឪពុក ដែលអង្គុយវេញខ្សែនៅលើផ្ទះ លោកឪពុកគ្រាន់តែឃើញខ្ញុំប្រឡាក់ដោយឈាម តាំងពីក្បាលដល់ជើង នៅលើទីបំផុតនៃមាត់ជណ្តើរ ក៏ស្ទុះមកចាប់ខ្ញុំដោយប្រញាប់ ។ ខ្ញុំមានការតក់ស្លុតជាខ្លាំង ដោយខ្លាចលោកឪពុកចាប់ខ្ញុំវាយ ព្រោះមិនចេះប្រយ័ត្ន ។ ការភ័យនេះ ខ្ញុំស្មើរតែរបូតដៃធ្លាក់ម្តងទៀត ។ លោកឪពុកចាប់ខ្ញុំបញ្ចិះលើស្មារត់ទៅយ៉ាងលឿន សំដៅទៅផ្ទះជីដូន ។ កាលនោះមិនមានពេទ្យទេ លោកឪពុកនិងអ្នកភូមិបានយកកន្ត្រៃមកកាត់សក់ចេញ និងយកម្ជុលចេសសម្រាប់ដេរខោអាវមកដេរទាំងស្រស់តែម្តង រួចទំពារស្លាចិញ្ចៀនបិទធ្វើជាថ្នាំ ឯចេសដែលដេរនោះ មិនបានហូតចេញទេ ប្រហែលជារលាយអស់ហើយ ។

លើកទី ៣ **សុជាខ្ញុំ**ធំបន្តិចហើយ រត់លេងបាល់ជាមួយក្មេង អ្នកស្រុក ក៏ជួលបោកនឹងថ្ម បែកចេញឈាមផ្នែកខាងក្រោយ តែមិន ខ្លាំងដូចលើកទី ២ ទេ ហើយថ្នាំព្យាបាល គឺស្មៅចិញ្ចៀនដដែល ។

ផ្នែកត្រង់មាត់និងធ្មេញ ដោយសារកាពរពីសរបស់ក្មេង ខ្ញុំបាន លោតចូលក្នុងធុងសាំងធំមួយ ដែលមានកម្ពស់ស្មើក្បាល ពេល លោត ដោយលំនឹងមិនល្អ ក៏បានបោកត្រូវចំមាត់ធុងនោះ មាត់ធុង រឹងជាងមាត់ខ្ញុំ បបូរមាត់ក៏បែក ធ្មេញខាងមុខរង្គើទាំងអស់ ឈាមហូរ រហាម អ្នកម្ដាយបានឲ្យខ្ញុំបៀមស្រាដើម្បីឲ្យស្ពឹក ។ ធ្មេញដែលធ្លាប់ តែល្អដូចធ្មេញកណ្ដុរ ក៏ក្លាយជាធ្មេញដូចសព្វថ្ងៃនេះ ។ នេះកាលខ្ញុំ នៅជាកុមារមុនបួស ។

ផ្នែកពោះ ធ្លាប់វះកាត់ខ្នែងពោះវៀនម្ដង ។ ជាធម្មតា ការ វះកាត់ខ្នែង គេចាត់ទុកថាជារឿងតូចតាចប៉ុណ្ណោះ តែចំពោះខ្ញុំ ប្រែក្លាយទៅជារឿងធំ គឺមុខរបួសមិនងាយជា បេះតែមានខ្ទុះ ត្រូវ រុះរើថ្នេរដេរឡើងវិញដល់ទៅពីរលើក សរុបទៅបីលើកទាំងពេល វះកាត់ផង ។ ពេលវះកាត់ **សុជាខ្ញុំ** ស្ថិតនៅក្នុងភេទជាភិក្ខុភាវៈ ។

# ការចូលសាងផ្នួស

***សុជាខ្ញុំ*** *មិនដែលនឹកស្រមៃថាចង់ចេញបួសទេ គោលគំនិតចង់ធ្វើជាគ្រូបង្រៀន ជាអ្នកចម្រៀង និងជាវិចិត្រករ ប៉ុន្តែខ្សែជីវិតបច្ចុប្បន្ន មិនឃ្លាតឆ្ងាយពីស្រមោលអតីត:ដែលជាឧបនិស្ស័យធ្លាប់សន្សំមកឡើយ ។ ល្ងាចថ្ងៃមួយ ក្នុងកាលដែលខ្ញុំមានអាយុ ១៥ ឆ្នាំ ជាពេលវិស្សមកាល បន្ទាប់ពីរៀននៅអនុវិទ្យាល័យបានមួយឆ្នាំ ខ្ញុំនៅខាងក្រោមផ្ទះ លោកឪពុកអង្គុយនៅលើផ្ទះបាយ ពិសារបាយបណ្តើរ និយាយនឹងខ្ញុំបណ្តើរថា “ ..........* ***ជាកូន!*** *ឪឃើញកូនឯងគ្មានកម្លាំងកំហែងដូចគេទេ ហើយឈឺច្រើនទៀត បើរកស៊ីចិញ្ចឹមជីវិតទៅដោយកម្លាំងបាយមិនកើតទេ ឪមានផ្លូវពីរឲ្យឯងជ្រើសរើស ទីមួយគឺត្រូវខំរៀន យ៉ាងហោចក៏ឲ្យបានធ្វើជាគ្រូបង្រៀនដែរ ឪនឹងខំតស៊ូរកលុយឲ្យកូនរៀន ទីពីរគឺទៅបួស តែមិនឲ្យបួសគ្រាន់តែចាំវត្តទេ គឺត្រូវទៅស្វែងរៀនសូត្រឲ្យបានចេះដឹងដូចតេជគុណ* ***សុង*** *តេជគុណ* ***ធុន*** *អ៊ីចឹង .....” កាលនោះ ព្រះសង្ឃពីរអង្គនេះ មានឈ្មោះល្បីថា ជាអ្នកចេះដឹងនៅក្នុងស្រុកនោះ ។ ឮដូច្នោះ ខ្ញុំក៏មានចំណង់ខ្លះក្នុងការចេញសាងផ្នួស ហើយក៏និយាយតបលោកឪពុកថា “.......... ចាំខ្ញុំទៅសួរលោកយាយសិន បើគាត់ពេញចិត្ត ល្ងាចនេះ ពេលមកពីស្រែវិញ*

ខ្ញុំមិនមកផ្ទះទេ ខ្ញុំនឹងទៅរៀនធម៌នៅឯវត្តតែម្តង ………” ល្ងាចនោះ ខ្ញុំយកបាយទៅជូនបងប្រុសនៅឯស្រែ បានឈៀងចូលទៅសួរជីដូនរបស់ខ្ញុំថា “ ………. លោកយាយ! បើខ្ញុំបួស តើលោកយាយគិតយ៉ាងណាដែរ? ” លោកយាយតបថា “ ….. បានចៅឯងបួស យាយត្រេកអរណាស់ …” ឮដូច្នោះ ខ្ញុំក៏សម្រេចចិត្តថា ត្រូវតែបួស ។ បន្ទាប់ពីយកបាយជូនបងប្រុសហើយ ខ្ញុំក៏រត់ទៅរៀនធម៌នៅឯវត្តទាំងយប់តែម្តង ។

បន្ទាប់ពីរៀនធម៌បានប្រហែលកន្លះខែ ថ្ងៃបព្វជ្ជាក៏ចូលមកដល់ គឺនៅថ្ងៃ សុក្រ ១៤ កើត ខែចេត្រ ព.ស.២៥៣៧ ត្រូវនឹងថ្ងៃទី ២២ ខែមេសា ឆ្នាំ ១៩៩២ ខ្ញុំក៏បានប្រែក្លាយពីកុមារ **សាន សុជា** មកជាសាមណេរ **សាន សុជា** ដោយមានព្រះភិក្ខុ **ញ៉ែម វ៉ាន់** ជាព្រះឧបជ្ឈាយ៍ ។

កាលនោះ មានកុលបុត្ត ៥ រូបផ្សេងទៀតបានបួសរួមគ្នាជាមួយនឹងខ្ញុំ ដូច្នេះសរុបទាំងខ្ញុំផងត្រូវជា ៦ រូប ។ ប៉ុន្តែគួរឲ្យអនិច្ចា សមណមិត្តរបស់ខ្ញុំ ៥ រូបនោះ បានលាចាកសិក្ខាបទព្រមទាំងមានប្រពន្ធកូនអស់ទៅហើយ នៅសល់តែ**សុជាខ្ញុំ**ប៉ុណ្ណោះ ហើយ**សុជាខ្ញុំ**ក៏មិនដឹងថា អាចតស៊ូបានយូរប៉ុណ្ណាទៀតទេ ។ ណ្ហើយ! ស្រេចតែលើហេតុបច្ច័យទៅចុះ ។

# វស្សាទី ១ *(ដើមឆ្នាំ ១៩៩២)*

*បុរាណតែងបានពោលថា “ នៅផ្ទះម្ដាយទីទៃ ទៅព្រៃម្ដាយតែមួយ ” ពិតដូច្នោះមែន ពេលនោះ* ***សុជាខ្ញុំ****មិនមែនជាមនុស្សមានសេចក្ដីក្លាហានប៉ុន្មានទេ ថ្វីដ្បិតតែបំណងនៃការបួស គឺដើម្បីចេញទៅសិក្សាមែន ប៉ុន្ដែមិនដឹងថាត្រូវសិក្សាអ្វី ឬត្រូវទៅសិក្សានៅទីណាឡើយ ណាមួយមិនស្គាល់គេឯង មិនស្គាល់ទីកន្លែង និងភ័យខ្លាចមិនហ៊ានដើរផ្លូវឆ្ងាយ ព្រោះកាលនោះ ស្រុកខ្មែរយើងមិនទាន់ចប់សង្គ្រាមនៅឡើយទេ ។ ដូច្នេះជីវិតយើងម្នាក់ ៗ មុននឹងបានសម្រេចគោលដៅអ្វីមួយ មិនមែនបានដោយចៃដន្យ ឬបានដោយឯង ៗ ទេ គឺត្រូវតែមានចំណុចចាប់ផ្ដើម ត្រូវតែមានអ្នកបង្ហាញផ្លូវ ។ ឯចំណុចចាប់ផ្ដើមនៃការសិក្សាក្នុងភាពជាអ្នកបួសនៃ* ***សុជាខ្ញុំ*** *មានដូចតទៅ ។*

*បន្ទាប់ពីបួសបានប្រហែល ១ ខែ រាត្រីថ្ងៃមួយ ខ្ញុំសុបិនឃើញថា បានជិះលើដំបូលឡានដ៏ធំមួយជាមួយព្រះភិក្ខុមួយអង្គព្រះនាម* ***ស៊ិន សុផន***[១] *ចេញពីវត្តដែលខ្ញុំគង់នៅឆ្ពោះទៅកាន់ទិស*

---

១.ព្រះភិក្ខុ ស៊ិន សុផន ដោយសារលោកជាកូនពៅក្នុងគ្រួសារ មិនធ្លាប់មានប្អូន កាលខ្ញុំទើបតែបួស លោកបានសុំខ្ញុំធ្វើជាប្អូន ហើយបានសន្យានឹងខ្ញុំថា ទោះបីមានហេតុយ៉ាងណាក៏ដោយ លោកនៅតែស្រឡាញ់រាប់អានខ្ញុំឱ្យដូចជាប្អូនបង្កើតរហូតដល់ចាស់ស្លាប់រៀងខ្លួន ។ លោកបានលាចាកសិក្ខាបទទៅហើយ សព្វថ្ងៃរស់នៅសហរដ្ឋអាមេរិក ។

ខាងជើង ។ លំដាប់នោះ ដោយឡានផ្អៀង ខ្ញុំក៏ធ្លាក់ទៅក្នុងប្រឡាយដែលមានទឹកល្អក់ឡើងក្រហមដូចពណ៌ដីស្អិត នៅប្របផ្លូវខាងលិច ។ ព្រះភិក្ខុ **ស៊ិន សុផន** ស្រែកប្រាប់ខ្ញុំថា “ នេន! ចាប់ឡើងមក!...” ខ្ញុំខំស្រវាឡើងយ៉ាងណាក៏ឡើងមិនរួចដែរ ។ វេលានោះ មានភិក្ខុមួយអង្គ រាងស្គមខ្ពស់ សម្បុរមិនស្វាយជាសប៉ុន្មាន យកជណ្ដើរឈើមកដាក់នឹងមាត់ប្រឡាយ ហើយប្រាប់ខ្ញុំថា “ នេនឯងឡើងតាមនេះមក! ” ខ្ញុំក៏បានឡើងរួច ។

ព្រឹកឡើង ពេលក្រោកពីសឹង ខ្ញុំបាននិយាយរឿងសុបិននោះប្រាប់សមណមិត្តទាំងឡាយរបស់ខ្ញុំតាំងពីដើមដល់ចប់ ។ គ្រាន់តែម៉ោងប្រហែល ១០ កន្លះព្រឹក ព្រះភិក្ខុដែលខ្ញុំបានឃើញក្នុងសុបិននោះក៏និមន្តមកដល់ ។ ខ្ញុំបាននិយាយប្រាប់សមណមិត្តរបស់ខ្ញុំថា ភិក្ខុអង្គនេះហើយ ដែលបានយកជណ្ដើរឲ្យខ្ញុំព្រះករុណាក្នុងយល់សប្ដិកាលពីយប់មិញ ។ ការលើកឡើងយ៉ាងនេះ គឺចង់បញ្ជាក់ថា ខ្ញុំបានស្គាល់លោកក្នុងសុបិន មុនពេលបានជួបព្រះភក្ត្រលោកមែនទែន ។

ប្រហែលមួយសប្ដាហ៍ក្រោយមក លោកក៏ចាប់ផ្ដើម បង្រៀនភាសាបាលីដល់ខ្ញុំព្រះករុណា និងសមណមិត្តទាំងឡាយ ។ លោកមានព្រះនាមថា ព្រះភិក្ខុ **ឡាយ យ៉ុល** ។ លោកមិនត្រឹមតែបង្រៀន

ប៉ុណ្ណោះទេ សូម្បីតែបច្ច័យបួន និងសុខទុក្ខរបស់សិស្ស ក៏តែងតែគិតគូរ ដូចឪពុកនិងកូនអ៊ីចឹង ។ ឯ**សុជាខ្ញុំ** ក៏បានតាំងនៅក្នុងឱវាទរបស់លោក និងគោរពប្រតិបត្តិលោកថាជាគ្រូទីមួយរបស់ខ្ញុំ តាំងពីពេលនោះមក ។ នេះគឺជាចំណុចចាប់ផ្តើមនៃការសិក្សារបស់ខ្ញុំ ក្នុងភេទជាបព្វជិត ។ ឆ្នាំទីមួយនោះ ខ្ញុំបានទន្ទេញចាំស្ទាត់រត់មាត់នូវបាលីវេយ្យាករណ៍ ៥ និទ្ទេស ក្នុងបណ្តាវេយ្យាករណ៍ទាំង ៧ និទ្ទេស គឺ អក្ខរវិធីនិទ្ទេសទី ១ នាមនិទ្ទេសទី ២ អាខ្យាតនិទ្ទេសទី ៥ កិតកនិទ្ទេសទី ៦ និងឧណាទនិទ្ទេសទី ៧ ដោយរំលងសមាសនិទ្ទេសទី ៣ និងតទ្ធិតនិទ្ទេសទី ៤ ។

ពេលជិតវ៉ាកង លោកគ្រូប្រាប់ថា លោកបង្រៀននៅទីនោះតែមួយវស្សាហ្នឹងទេ ខ្ញុំក៏សុំពឹងព្រះភិក្ខុ **ស៊ុន សុផន** ឲ្យជូនទៅរកកន្លែងសិក្សាជាបន្តនៅទីក្រុងភ្នំពេញ ប៉ុន្តែដោយបុណ្យមិនគ្រប់គ្រាន់ វត្តណាក៏មិនទទួលខ្ញុំឡើយ **សុជាខ្ញុំ**ត្រូវត្រឡប់ទៅស្រុកកំណើតវិញ ដោយសេចក្តីអស់សង្ឃឹម ។



សាមណេរ សាន សុជា កាលទើបតែបួស

## **វស្សាទី ២** *(ឆ្នាំ ១៩៩៣)*

*ដើមឆ្នាំ ១៩៩៣ សុជាខ្ញុំកាន់តែមានការអស់សង្ឃឹម ព្រោះសមណសិស្សថ្នាក់ទី ២ និងថ្នាក់ទី ៣ ត្រូវប្រឡងចូលទៅវិទ្យាល័យព្រះសុរាម្រឹត ឯសមណសិស្សដែលប្រលងធ្លាក់និងលោកគ្រូរបស់ខ្ញុំត្រូវមានដំណើរទៅឆ្ងាយ ។ មិនយូរប៉ុន្មានលោកក៏បានចេញទៅមែនតែលោកបានផ្ដាំថា "... នេនឯងទ្រាំនៅសិនចុះ កុំទៅណាមកណាអីហើយកុំសឹកណា មុនខ្ញុំក្តូណាចេញទៅឆ្ងាយ ខ្ញុំក្តូណានឹងធ្វៀតទាក់ទងទឹកន្លែងឲ្យ ..." រូបលោកក៏នាំគ្នាចេញទៅ ។ ឯ**សុជាខ្ញុំ** ក៏មានសេចក្តីសង្ឃឹមតិច ៗ ឡើងវិញ ។*

*មុនចូលវស្សាទី ២ លោកក៏បានត្រឡប់មកនាំ **សុជាខ្ញុំ** ព្រមទាំងសមណមិត្ត ៥ រូបទៀត ឲ្យទៅរៀននៅវត្តពន្លៃ ឃុំពន្លៃ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ដោយមានព្រះភិក្ខុ **កែវ ប្រុស** ជាអ្នកបង្រៀន ។ ក្នុងវស្សានោះ ខ្ញុំចាប់ផ្តើមប្រែគម្ពីរព្រះធម្មបទភាគទី១ និងរៀនវេយ្យាករណ៍បាលី អំពីសមាសនិទ្ទេស ទី ៣ រួមជាមួយមុខវិជ្ជាផ្សេងៗ ទៀត មានគណិតវិទ្យាជាដើម ។*



កាលទៅសិក្សានៅវត្តពន្លៃ ខេត្តកំពង់ឆ្នាំង

ពេលចេញវស្សា ដោយនឹករលឹកដល់គ្រូដើម ខ្ញុំក៏សុំចេញពីវត្តពន្លៃទៅស្នាក់រៀនជាមួយលោកជាបន្ត នៅវត្តស្វាយដូនកែវ ស្រុកបាកាន ខេត្តពោធិ៍សាត់ ដោយមានសមណសិស្សប្រមាណជាង ៧០ រូប ។ ពេលនោះខ្ញុំគ្មានថ្នាក់ ពិតប្រាកដទេ គឺពេលយប់ប្រែគម្ពីរធម្មបទភាគទី ៧ និងទី ៨ ជាមួយលោកគ្រូខ្ញុំ ដល់ពេលថ្ងៃបានពឹងពាក់ព្រះថេរៈចាស់ ៗ ឲ្យលោកជួយប្រែគម្ពីរធម្មបទពីភាគក្រោម ៗ ទៅដើម្បីធាប់ចប់ ។ ខ្ញុំស្នាក់រៀន នៅទីនោះបានប្រហែល ២ ខែ ឃើញថាភាសាបាលីរបស់ខ្ញុំហាក់ដូចជាគ្រាន់បើជាងមុនច្រើន តែមុខវិជ្ជាផ្សេង ៗ សម្រាប់ជំនួយដល់ការប្រលងចូលទៅវិទ្យាល័យព្រះសុរាម្រឹត ដូចជាគណិតវិទ្យាជាដើមមិនទាន់ពូកែ និងដោយឮដំណឹងថា នៅឯវត្តប្រាសាទ ឃុំតានី ស្រុកអង្គរជ័យ ខេត្តកំពត មានព្រះភិក្ខុមួយអង្គព្រះនាម **នួន** ធ្លាប់រៀនបានថ្នាក់ខ្ពស់កាលនៅជាគ្រហស្ថ លោកអាចជួយបង្រៀនមុខវិជ្ជាផ្សេង ៗ បាន ។ ខ្ញុំក៏ធ្វើដំណើរទៅវត្តនោះជាមួយនឹងព្រះភិក្ខុ **ប៉ុក ជា** ជាសិស្សច្បងរបស់ខ្ញុំ និងសាមណេរ **សែស សូជា** ជាមិត្តរួមថ្នាក់របស់ខ្ញុំ ។ ក្នុងកាលនោះខ្ញុំក៏បានរៀនមុខវិជ្ជាផ្សេង ៗ មានគណិតវិទ្យាជាដើម និងប្រែគម្ពីរជាបន្ត ដោយមានព្រះភិក្ខុ **ប៉ុក ជា** ជាអ្នកជួយបកប្រែ ។




ក្រោយពេលដែលខ្ញុំចាកចេញទៅបានប្រហែលកន្លះខែ ដោយខ្វះខាតបច្ច័យខ្លាំងពេក គ្រូរបស់ខ្ញុំនិងសមណសិស្សទាំងអស់ បាន

ចាកចេញពីវត្តស្វាយដូនកែវ ដោយចែកជាពីរក្រុមគឺ ៖ មួយក្រុមទៅស្នាក់នៅវត្តពាលញែក ឃុំផ្ទះព្រៃ ដោយលោកគ្រូរបស់ខ្ញុំជាអ្នកបង្រៀន មួយក្រុមទៀត ទៅស្នាក់នៅវត្តព្រែកស្ពឺ ឃុំរលកស ដោយមានព្រះភិក្ខុធម្មបាល **សុខ រ៉ុប** ជាអ្នកបង្រៀន ហើយវត្តទាំងពីរនេះស្ថិតនៅក្នុងស្រុកសំពៅមាស ខេត្តពោធិ៍សាត់ ។ ខ្ញុំស្នាក់រៀននៅវត្តប្រាសាទបានប្រហែលមួយខែ ក៏ត្រឡប់មកខេត្តពោធិ៍សាត់ម្តងទៀត ដោយស្នាក់នៅវត្តពាលញែក សិក្សាក្នុងសំណាក់គ្រូរបស់ខ្ញុំជាបន្តទៀត រហូតដល់ពេលប្រឡងតែម្តង ។

មានអ្នកខ្លះយល់ច្រឡំថា ក្នុងកាលណោះ **សុជាខ្ញុំ**បានស្នាក់នៅក្នុងវត្តព្រែកស្ពឺ ប៉ុន្តែការពិតមិនដូច្នោះទេ ខ្ញុំសូមជម្រាបថា ខ្ញុំមិនធ្លាប់បានស្នាក់នៅវត្តព្រែកស្ពឺទេ គ្រាន់តែធ្លាប់ទៅលេងសមណមិត្តរបស់ខ្ញុំ ២ ឬ ៣ ដង តែប៉ុណ្ណោះ ។

នៅថ្ងៃទី ៥ ខែ មិនា ឆ្នាំ១៩៩៤ ខ្ញុំបានប្រលងជាប់ វិញ្ញាបនប័ត្រនៃសាលាពុទ្ធិកបឋមសិក្សា នៅមណ្ឌលប្រលងភ្នំពេញ ។




ក្នុងឆ្នាំនោះដដែល ក្រោយពេលបានទទួលវិញ្ញាបនបត្ររង រួចហើយ ខ្ញុំក៏បានប្រលងចូលសិក្សានៅវិទ្យាល័យព្រះសុរាម្រឹត

រាជធានីភ្នំពេញ ជាសិស្សជំនាន់ទី ២ ។ ពេលនោះហើយ ដែលក្នុងជីវិតតម្រូវឲ្យ**សុជាខ្ញុំ** មានសេចក្ដីតស៊ូកាន់តែខ្លាំងឡើង ។

មកដល់ភ្នំពេញដំបូង មិនទាន់មានកុដិស្នាក់នៅត្រឹមត្រូវទេ ។ ដោយស្គាល់សមណសិស្សជំនាន់ទី ១ ដែលជាសិស្សច្បងរបស់ខ្ញុំ គង់នៅកុដិលេខ ១១ នៃវត្តឧណ្ណាលោម ខ្ញុំក៏យកអីវ៉ាន់ទៅផ្ញើនៅកុដិនោះ ហើយសុំសឹងនៅរបៀងកុដិខាងក្រៅ ។ ប៉ុន្តែក្រោយមក ដោយធ្លាប់រាប់អានព្រះភិក្ខុមួយអង្គព្រះនាម **ស៊ុន សុផន** រាល់ពេលរាត្រី លោកបានហៅខ្ញុំទៅសឹងលើគ្រែជាមួយលោក លុះដល់ពេលថ្ងៃខ្ញុំនៅតែមិនមានទីកន្លែងពិតប្រាកដដដែល ។ ខ្ញុំរស់នៅក្នុងសភាពបែបនេះអស់រយៈពេលជាច្រើនខែ ។

ក្រោយមក ដោយទ្រាំទឹងជីវភាពបែបនេះមិនបាន គ្រូរបស់ខ្ញុំរួមនឹងសមណមិត្តទាំងឡាយ បានទៅរៀបរាប់ពីទុក្ខលំបាករបស់ខ្លួនចំពោះព្រះមេគណខេត្តតាកែវ ។ ព្រះមេគណក៏មានព្រះទ័យអាណិត ហើយលោកក៏បានធ្វើច្បាប់ស្នើសុំគណៈគ្រប់គ្រងវត្តឧណ្ណាលោម ឲ្យប្រគល់កុដិលេខ ២៩ មកសមណសិស្សខេត្តតាកែវស្នាក់នៅ ។ គណៈគ្រប់គ្រងវត្តឧណ្ណាលោម ក៏បានប្រគល់ឲ្យតាមសំណើរ ប៉ុន្តែមិនទាន់បានទៅនៅកុដិនោះភ្លាម ៗ ទេ ព្រោះក្រោយថ្ងៃរំដោះ ក្រសួង

អប់រំមិនមានសាលាគ្រប់គ្រាន់ បានយកកុដិព្រះសង្ឃដោយច្រើនក្នុងវត្តឧណ្ណាលោម ធ្វើជាសាលាបង្រៀនក្មេងជាបណ្ដោះអាសន្ន ។ ដូច្នេះ ត្រូវរង់ចាំគេផ្លាស់ប្ដូរសាលារួចសិន ទើបទៅនៅបាន ។ ពេលវេលានៃការរង់ចាំកាន់តែយូរទៅ ៗ ស្ថានភាពរស់នៅក៏កាន់តែលំបាកទាំងអស់គ្នាក៏ធ្វើច្បាប់សុំម្ដងទៀត ។ ក្រោយពេលបានទទួលសំណើរថ្នាក់លើក៏បានចុះមកដោះស្រាយឲ្យ ប៉ុន្ដែមិនបានទាំងស្រុងទេ បានប្រហែលត្រឹមមួយភាគបួននៃកុដិប៉ុណ្ណោះ ។

ពេលបានមកនៅកុដិលេខ ២៩ នឹកស្មានថាបានធូរស្រាលជាងមុន ប៉ុន្ដែលទ្ធផលគឺកាន់តែលំបាកពណ៌នា ។ សមណសិស្សដែលជាភិក្ខុបានគង់នៅជាន់ខាងលើ ខ្ញុំនិងសមណមិត្ត ២ អង្គទៀតដែលជាសាមណេរស្នាក់នៅខាងក្រោម (ជាន់ផ្ទាល់នឹងដី) ជាកន្លែងដែលគេចាក់សំរាមចោល ដោយមិនមានទ្វារបង្អួច មិនមានទឹក ភ្លើងនិងបង្គន់ទេ ។ ទឹក និងបង្គន់ ត្រូវទៅសុំប្រើប្រាស់នៅកុដិដទៃ ។ កាលនោះ គឺ ..........................................................................

..........................................................................................

..........................................................................................

........................................................................................ ។

ប្រហែលមួយឆ្នាំក្រោយ ទើបគេប្រគល់កុដិលេខ ២៩ ឲ្យទាំងស្រុង ។ ចាប់ពីពេលនោះមក កន្លែងស្នាក់នៅក៏បានប្រសើរជាងមុន ប៉ុន្តែជីវភាពនៅតែលំបាកដដែល ព្រោះមិនធ្លាប់បានគេនិមន្តទៅសូត្រមន្ត ឬទេសនាតាមបុណ្យផ្សេង ៗ ឡើយ ។ រាល់ថ្ងៃ ៧-៨ និង ១៤-១៥ រនោច-ខ្នើត ដោយសម្រាកពីការសិក្សា ខ្ញុំបានជិះម៉ូតូឌុបទៅបិណ្ឌបាតនៅឯជាយក្រុង ព្រោះខ្ញុំមិនហ៊ានដើរបិណ្ឌនៅក្នុងក្រុងទេ គឺដោយសារតែភាពអៀនខ្មាស់ ។ រាល់ពេលទៅបិណ្ឌនោះ មិនមែនបានត្រឹមតែចង្ហាន់ប៉ុណ្ណោះទេ ថែមទាំងបានប្រាក់ខ្លះ ៗ សម្រាប់ដោះស្រាយជីវភាពរួច ៥ ថ្ងៃនៃសប្តាហ៍ ។ សមណមិត្តរបស់ខ្ញុំធ្លាប់ហៅខ្ញុំថា ជាមនុស្សអាចម៍ក្អាប់ ។ ប្រហែលជាត្រូវទេដឹង ព្រោះខ្ញុំមិនដែលចំណាយប្រាក់ទៅលើអ្វីក្រៅពីជីវភាពប្រចាំថ្ងៃ និងសម្រាប់ទិញសៀវភៅសិក្សាឡើយ ដោយហោចទៅ សូម្បីតែទឹកអំពៅមួយថង់តម្លៃមួយរយរៀល ក៏មិនហ៊ានទិញឆាន់ដែរ ។

ដល់ពេលវិស្សមកាល ខ្ញុំបានទៅតាមជនបទផ្សេង ៗ ដើម្បីស្វែងរកអង្ករ និងបច្ច័យបួនខ្លះសម្រាប់ប្រើប្រាស់ក្នុងការសិក្សាជាបន្តក្នុងបវេសនកាលថ្មី ។


កាលសិក្សានៅវិទ្យាល័យព្រះសុរាម្រឹត


ពេលវិស្សមកាល ទៅប្រែគម្ពីរនៅវត្តព្រះធាតុ


ភាពកំសត់ ៥ ឆ្នាំនៅភ្នំពេញ

ភាពលំបាកនៅភ្នំពេញ ប្រសិនបើមិនមានការជ្រោមជ្រែងអំពីគ្រូរបស់ខ្ញុំទេ ខ្ញុំក៏មិនអាចតស៊ូបានដែរ ។ ការរៀបរាប់មកនេះមិនទាន់អស់រឿងដែលត្រូវនិយាយទេ ប៉ុន្តែចំណុចខ្លះប្លែងមិនរួចទើបខ្ញុំសូមមិននិយាយ ។

តាមពិត ក្នុងជីវិតរបស់សមណៈ មិនគួរត្អូញត្អែរច្រើនពេកទេ ព្រោះហេតុដូច្នេះ ខ្ញុំសូមមិននិយាយអំពីបញ្ហាលំបាកតទៅទៀតទេ ដើម្បីកុំឲ្យជីវប្រវត្តិនេះមានសេចក្ដីវែងពេក ។

រយៈពេល ៤ ឆ្នាំក្រោយមក ខ្ញុំបានប្រលងជាប់វិញ្ញាបនប័ត្រមធ្យមសិក្សាបឋមភូមិ នៃសាលាពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ។

ក្រោយពេលប្រលងចេញហើយ ខ្ញុំមិនបានសិក្សាបន្តទៅថ្នាក់លើទេ ព្រោះពេលនោះ គឺជាពេលដែលខ្ញុំចាប់ផ្ដើមរារែកផ្លូវចិត្ត មិនអាចកំណត់ផ្លូវនៃជីវិតសម្រាប់ដើរដោយខ្លួនឯងបាន ម្យ៉ាងចង់រៀនជាបន្ត ម្យ៉ាងចង់ដើរតាមមាគ៌ាព្រះធម៌ ។ កាលនោះខ្ញុំចាំបានថា ខ្ញុំធ្លាប់ទៅសូមអនុញ្ញាតអំពីញោមប្រុសស្រីរបស់ខ្ញុំ ដើម្បីទៅធ្វើធុតង្គនៅក្នុងព្រៃរហូតអស់មួយជីវិត ប៉ុន្តែញោមទាំងពីរមិនអនុញ្ញាត ។ ខ្ញុំក៏ស្នាក់នៅភ្នំពេញជាបន្ត ដើម្បីសិក្សាភាសាបរទេស ដូចជាអង់គ្លេស និងភាសាថៃជាដើម ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
+++++++++++

ក្រសួងធម្មការ និងសាសនា

លេខ ៥៨/៩៨.... ក.ធ.ស.

## សញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិ

ក្រសួងធម្មការ និងសាសនាបញ្ជាក់ថា សមណសិស្សឈ្មោះ [illegible]

ជាតិ ខ្មែរ កើតនៅថ្ងៃទី 12 ខែ [illegible] ឆ្នាំ 1978

នៅឃុំ ឬ សង្កាត់ គោកពោធិ៍ ស្រុក បូរីជលសារ ខេត្ត តាកែវ

ឪពុកឈ្មោះ [illegible] ម្តាយឈ្មោះ [illegible]

បានប្រឡងជាប់ **សញ្ញាបត្រពុទ្ធិកមធ្យមសិក្សា**

នៅមណ្ឌល **ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត** សម័យប្រឡង 15.16.17 **ខែមករា ឆ្នាំ ១៩៩៨**

បន្ទប់លេខ III លេខតុ 55 និទ្ទេស ល្អបង្គួរ

**ក្រសួងបានចេញសញ្ញាបត្រនេះអោយសាមីខ្លួនប្រើប្រាស់តាមការដែលអាចប្រើបាន ។**

រាជធានីភ្នំពេញ ថ្ងៃទី 17 ខែ [illegible] ឆ្នាំ ១៩៩៨

រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា

[illegible]



កំណត់សំគាល់ : សញ្ញាបត្រនេះគ្មានចេញប្រគេនជាលើកទីពីរទេ

ក្រោយពីការសិក្សានៅពុទ្ធិកៈ ខ្ញុំក៏បានយល់ដឹងខ្លះ ៗ អំពីសង្គម ដូចជាសិទ្ធិមនុស្សជាដើម ។


LICADHO

CAMBODIAN LEAGUE FOR THE PROMOTION AND THE DEFENCE OF THE HUMAN RIGHTS

LICADHO'S TRAINING PROGRAM

A CERTIFICATE FOR ATTENDING THE BASIC HUMAN RIGHTS ( LEVEL )

Phnom Penh PROVINCE

FROM : 19 September 1994 TO 30 September 1994

IS AWARDED TO

NAME : SAN SOCHHEA

DATE OF ISSUE : 31 September 1994

TRAINER

PUNG CHHIV KEK
President of LICADHO



ស៊ី អូ អេច ឌី

អង្គការជាតិកម្ពុជាដើម្បីសិទ្ធិមនុស្ស និង អភិវឌ្ឍន៍

Cambodia Organization for Human Rights and Development

ស៊ីអូអេចឌី COHD

COHD

**លិខិតបញ្ជាក់ការសិក្សា**

បានប្រគេន និង ប្រគល់ជូន :......ភិក្ខុ.ធម៌រម្យញ្ញោ សាន សុជា...... ព្រះជន្ម / អាយុ ......២៨...... វស្សា / ឆ្នាំ

ប្រសូត/កើតនៅថ្ងៃទី ...២៥..... ខែ ....ឧសភា.....ឆ្នាំ ១៩៧៧. ភូមិ .......អ្នកតាឡាល់..... ឃុំ / សង្កាត់ .....គោគពោធិ៍............

ស្រុក / ខណ្ឌ .........បូរីជលសា.......... ខេត្ត / ក្រុង ........តាកែវ................ ព្រះបរមងារ / ឋានៈ អធិបតីសិក្សាព្រះពុទ្ធសាសនាមណីរត្ន

គង់ / នៅវត្ត ..........មជ្ឈមណ្ឌលមណីរត្ន............ ភូមិ .....ថ្មល់បំបែក......................... ឃុំ / សង្កាត់ ......រលាប..................

ស្រុក / ខណ្ឌ .........សំពៅមាស.................................. ខេត្ត / ក្រុង ......ពោធិ៍សាត់..................................................

ដែលបានបញ្ចប់ដោយជោគជ័យក្នុងការចូលរួម ការពង្រឹងគំរោងស្ថាបនាឡើងវិញ ជាមួយព្រះសង្ឃស្តីពី " ការរើសអើង ជាមួយអ្នកផ្ទុកមេរោគអេដស៍ និង ក្រុមគ្រួសារ នៅខេត្តពោធិ៍សាត់ " ។

ចាប់ពីថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៤ រហូតដល់ ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៤

រយៈពេល ពីរថ្ងៃ ( ចំនួន ១០ ម៉ោង ) ។

លិខិតបញ្ជាក់នេះ ទុកជាសក្ខីភាព នៃសាមីអង្គ / ជនដែលបានព្យាយាមក្នុងវិជ្ជាជីវៈ ។

នាយកប្រតិបត្តិ

គីម សាន



ខ្មែរស្ម័គ្រចិត្ត ដើម្បីអភិវឌ្ឍន៍សហគមន៍

**Cambodian Volunteers for Community Development**

CERTIFICATE OF COMPUTER TRAINING COURSE

THIS IS TO CERTIFY THAT ***SAN SOCHEAT*** SEX : ***Male***

NATIONALITY : ***Cambodian*** RACE: ***Khmer***

DATE OF BIRTH: **May 12 , *1978***

PLACE OF BIRTH: ***Takeo Province***

AND HAS SUCCESSFULLY COMPLETED THE PROGRAMS OF ***Typing , MS-DOS , Microsoft Office'97, Microsoft Word'97, Microsoft Excel'97, Scan Virus*** FOR THE PERIOD OF: ***January 1, 1998*** TO: ***May 29, 1998.***

THE COURSE COMPRISED (Lectures & Hands-on=29 hours, Computer Practice = 59 hours )

**Date: June 24 , 1998**

**Sothea Arun**
**CVCD Representative**

**Vong Ravuth**
**Teacher**

Sponsored by the Cambodian Volunteers for Community Development (CVCD), Khmer Culture Institue (KCI) and taught by qualified instructors.
CVCD is supported by PACT, which is funded by United States Agency for International Development ( USAID ).

The Australian Centres for Development

# THIS IS TO CERTIFY THAT



**Mr. San Sochea**

*has satisfactorily completed*

**Intermediate**

*A multi-level English Language Course*
*at*
*The Australian Centres for Development*

№ BTB. 00174

Henk de Jong, Manager

*on behalf of* ACD *Cambodia*

Province and Date of Issue
Pursat, 25 April 2006

**Education Australia**

ACD *Cambodia's Human Resource Development Experts !*

កម្រិតនៃការសិក្សារបស់ខ្ញុំ មានត្រឹមប៉ុណ្ណេះឯង បើប្រៀបទៅនឹងសម័យជឿនលឿន មិនគួរបើនឹងលើកមកនិយាយឡើយ ។

## ការចេញបង្រៀន

នៅថ្ងៃ ១៤ រោច ខែចេត្រ នព្វស័ក ព.ស.២៥៤១ ត្រូវនឹងថ្ងៃទី ២១ ខែមេសា ឆ្នាំ ១៩៩៧ ខ្ញុំបានឧបសម្បទាជាភិក្ខុភាវៈក្នុងសំណាក់ព្រះឧបជ្ឈាយ៍របស់ខ្ញុំដដែល ។

ក្រោយពេលឧបសម្បទាបាន ២ វស្សា គឺនៅដើមឆ្នាំ ១៩៩៩ (មិនចាំថ្ងៃខែច្បាស់លាស់) គ្រូរបស់ខ្ញុំបានចាត់ឲ្យខ្ញុំទៅបង្រៀនសមណសិស្សនៅវត្តពោធិមន្ត្រី ឃុំគោកពោធិ៍ ស្រុកបូរីជលសា ខេត្តតាកែវ ដែលជាស្រុកកំណើតរបស់ខ្ញុំ ជាមួយនឹងព្រះភិក្ខុធម្មសក្កត្ថេរោ **កុម សុវណ្ណ** លោកជាអ្នកបង្រៀនព្រះវិន័យ ខ្ញុំជាអ្នកបង្រៀនភាសាបាលី និងគណិតវិទ្យា ។ ក្នុងកាលនោះមានសមណសិស្សប្រមាណជាង ៥០ អង្គ ។

កាលពីមុន វត្តនោះមានភិក្ខុសាមណេរតែ ៥ អង្គ ហើយមិនមានចង្ហាន់បរិបូណ៌ឡើយ ប៉ុន្តែពេលខ្ញុំបើកបង្រៀន ព្រមទាំងមានសមណសិស្សដល់ទៅជាង ៥០ អង្គ បែរជាចង្ហាន់បរិបូណ៌ទៅវិញ ។

មិនត្រឹមតែពុទ្ធបរិស័ទជើងវត្តទេ សូម្បីពុទ្ធបរិស័ទនៅទីឆ្ងាយ ៗ ក៏ជ្រះថ្លា នាំគ្នាជួយឧបត្ថម្ភសមណសិស្ស លើសពីការស្មានរបស់ខ្ញុំ ។

ក្នុងឆ្នាំនោះដដែល ក្រសួងធម្មការនិងសាសនា បានប្រកាសប្រឡងជ្រើសរើសគ្រូ ដោយយកត្រឹមសញ្ញាប័ត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិ ។ ឮដូច្នោះ ខ្ញុំក៏បានធ្វើដំណើរទៅប្រឡងនៅរាជធានីភ្នំពេញ ហើយក៏បានជាប់ដូចសេចក្តីប្រាថ្នា ។

ក្រោយពេលប្រឡងជាប់ ក្រសួងតម្រូវឲ្យទៅរៀនផ្នែកគរុកោសល្យបន្ថែមចំនួន ១ ខែ ប៉ុន្តែខ្ញុំមិនទាន់បោះបង់ចោលនូវការបង្រៀននៅឯខេត្តតាកែវទេ ។

ចុងឆ្នាំ ១៩៩៩ ក្រោយពេលរៀនគរុកោសល្យចប់ ក្រសួងបានចាត់ឲ្យគ្រូទាំង ៣០ រូបទៅបង្រៀននៅតាមបណ្តាខេត្តនានា ដោយខេត្តមួយគ្រូមួយ សល់ប៉ុន្មានទុកឲ្យធ្វើការនៅក្រសួង ។

ក្នុងកាលនោះ ក្រសួងបានបើកឱកាសឲ្យគ្រូទាំងអស់ជ្រើសរើសយកខេត្តដែលខ្លួនចង់ទៅ ប៉ុន្តែការជ្រើសរើសមិនអាចសម្របសម្រួលគ្នាបាន ក៏ធ្វើពិធីចាប់ឆ្នោត ហើយខ្ញុំចាប់បានឈ្មោះខេត្តពោធិ៍សាត់ ជាខេត្តដែលខ្ញុំមិនធ្លាប់មានបំណងចង់ទៅ ។ ទោះជា

យ៉ាងណា ខ្ញុំមិនអាចប្រកែកបានឡើយ ព្រោះជាលទ្ធផលនៃការចាប់ឆ្នោត ដូចពាក្យចាស់ពោលថា “ស្អប់ជំពប់លើ” នោះឯង ។

ដើមឆ្នាំ ២០០០ ខ្ញុំបានទៅបង្រៀននៅសាលាពុទ្ធិកបឋមសិក្សាវត្តពាលញែក ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ ។ ក្នុងពេលទំនេរ ខ្ញុំបានបើកបង្រៀនភាសាអង់គ្លេសដល់យុវសិស្សទាំងឡាយដែលមកពីអនុវិទ្យាល័យពោធិ៍សាត់ ដោយបញ្ចូលការអប់រំសីលធម៌ផងដែរ ។

ដើមឆ្នាំ ២០០១ ខ្ញុំបានទៅបង្រៀននៅសាលាពុទ្ធិកបឋមសិក្សាវត្តកែវសុវណ្ណ ឃុំបន្ទាយដី ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់ ។



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងធម្មការ និង សាសនា

# វិញ្ញាបនបត្រគរុកោសល្យពុទ្ធិកបឋមសិក្សា

អធិការពុទ្ធិកសិក្សា នៃក្រសួងធម្មការ និង សាសនា

បញ្ជាក់ថា ឈ្មោះ ........សាន ~ សុខា...... ភេទ ប្រុស. កើតនៅថ្ងៃទី ១២.. ខែ ធ្នូសភា. ឆ្នាំ១៩៧៨
នៅឃុំ_សង្កាត់ គោកពោធិ៍ ស្រុក_ខ័ណ្ឌ បូរីជលសារ ខេត្ត_ក្រុង តាកែវ....បានសិក្សាក្នុង វគ្គគរុកោសល្យពុទ្ធិកបឋមសិក្សា
ជំនាន់ទី II ពីថ្ងៃទី១៥ ខែកញ្ញា ដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩៩ នៅសាលាគរុកោសល្យ ក្រសួងធម្មការ និង សាសនា ។
បានទទួលនិទ្ទេស : ..មធ្យម
ចុះបញ្ជីលេខ ...១៦៥..........

បានឃើញ
ភ្នំពេញ ថ្ងៃទី ១៥ ខែតុលា ឆ្នាំ ១៩៩៩
រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា
ជំ-សាវឿន

ភ្នំពេញ . ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៩
អធិការពុទ្ធិកសិក្សា
អ៊ឹម ស៊ិម

# ការប្រែក្លាយជាគ្រូបង្រៀនធម៌

*ដើមឆ្នាំ ២០០១ នោះ ខ្ញុំបានចាប់ផ្តើមបង្រៀនសមណសិស្ស នៅវត្តកែវសុវណ្ណ ។ ដើម្បីសម្រួលការងារនោះ ខ្ញុំបាននិមន្តព្រះភិក្ខុ សុវណ្ណបញ្ញោ* **ប៊ុក ជា**[១] *ជាសិស្សច្បងរបស់ខ្ញុំ ឲ្យមកជួយ ។*

*ក្រៅពីការបង្រៀននៅសាលាពុទ្ធិកៈ ខ្ញុំបានទទួលសម្តែងធម៌ តាមកម្មវិធីបុណ្យជាច្រើនកន្លែង ។ ពុទ្ធបរិស័ទបានសរសើរថា ខ្ញុំពូកែពន្យល់គ្រាន់បើ ។*

*ខ្ញុំចាំបានថា រសៀលថ្ងៃមួយ មានឧបាសិកាពីររូប ចូលមក សុំឲ្យខ្ញុំបង្រៀនធម៌ដល់ពុទ្ធបរិស័ទ ។ ខ្ញុំប្រកែកថា "មិនកើតទេដឹង!" គាត់បន្តថា "ខ្ញុំព្រះករុណាឃើញថាកើតទើបនិមន្ត ........" ។ ទីបញ្ចប់ ខ្ញុំឆ្លើយតបថា "ចាំអាត្មាគិតមើលសិន" ។ ចាប់ពីពេលនោះមក ទោះស្ថិតក្នុងឥរិយាបថណាក៏ខ្ញុំយកបញ្ហានោះមកគិតថា "កើត ឬ មិនកើត" ព្រោះជំនាញរបស់ខ្ញុំមិនមែនជាអ្នកបង្រៀនធម៌ទេ គឺជា អ្នកបង្រៀនផ្នែកពុទ្ធិកៈ មានភាសាបាលីជាដើម ។*

---

១-ដើមឡើយលោកមានឈ្មោះថា **ប៊ុក ជា** ប៉ុន្តែដើម្បីកុំឱ្យច្រឡំឈ្មោះគ្នា ខ្ញុំក៏សូមឱ្យលោកប្តូរឈ្មោះថា **ប៊ុក ស៊ីម** ដូច្នេះវិញ ។

ប្រហែលមួយសប្តាហ៍ក្រោយ ខ្ញុំបានឆ្លើយតបទឹងឧបាសិកាទាំងពីររូបថា “អាត្មានឹងសាកល្បងមើល .........” ។ ក្រោយពីការពិភាក្សាគ្នារួចហើយ នៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ ២០០១ ខ្ញុំរួមជាមួយនឹងគណៈកម្មការវត្តបានធ្វើសំណើរ សុំច្បាប់បង្កើតកន្លែងសិក្សាមួយមានឈ្មោះថា មជ្ឈមណ្ឌលសិក្សាអប់រំពុទ្ធសាសនា (Buddhist Education Center) ដែលមានទីតាំងនៅក្នុងវត្តកែវសុវណ្ណនោះឯង ។ មួយខែក្រោយមក ខ្ញុំក៏ចាប់ផ្តើមបង្រៀនពុទ្ធបរិស័ទអំពីកងធម៌ផ្សេង ៗ ដោយមួយសប្តាហ៍បង្ហាត់ ៣ ថ្ងៃ គឺសុក្រ សៅរ៍ និងអាទិត្យ ។ កាលបើបើកបង្រៀនព្រះធម៌បានដូច្នេះខ្ញុំក៏កាន់តែមានការរវល់ច្រើន មិនអាចបង្រៀននៅសាលាពុទ្ធិកៈបានជិតដល់ទេ ។ ដើម្បីសម្រួលការងារនេះ ខ្ញុំបានប្រគល់ការងារបង្រៀនភាសាបាលីឲ្យព្រះភិក្ខុ សុវណ្ណបញ្ញោ **ប៉ុក ស៊ុម** ជាអ្នកធ្វើជំនួសឯខ្ញុំនៅជួយបង្ហាត់មុខវិជ្ជាផ្សេង ៗ ដូចជាគណិតវិទ្យា និង ព្រះវិន័យជាដើម ។ ចាប់ពីពេលនោះមក ការបង្រៀនព្រះធម៌មានការលូតលាស់គួរជាទីកត់សម្គាល់ ។

ក្នុងការបង្រៀននោះ ខ្ញុំក៏បានថតសម្លេងទុកផងដែរ ប៉ុន្តែមិនមានបំណងថា យកទៅផ្សព្វផ្សាយទេ គ្រាន់តែចង់ដឹងថា តើការ

សម្ដែងរបស់ខ្លួនមានកម្រិតប៉ុនណា ហើយបើមានការខុសឆ្គង នឹងខិតខំកែតម្រូវឡើងវិញតែប៉ុណ្ណោះ ។ ការធ្វើរបៀបនេះ នាំឲ្យខ្ញុំទទួលបាននូវបទពិសោធន៍ក្នុងការសម្ដែងកាន់តែប្រសើរឡើង ។

ប្រហែលពីរខែក្រោយមក ដើម្បីឲ្យខ្សែព្រះធម៌មានលំដាប់លំដោយ ខ្ញុំបានលើកយកមង្គល ៣៨ ប្រការមកបង្រៀន ។ ការងាររបស់ខ្ញុំនៅពេលនោះ ប្រព្រឹត្តទៅយ៉ាងស្រួល គឺមិនលំបាកក្នុងការស្រាវជ្រាវប៉ុន្មានឡើយ ព្រោះជាធម៌ដែលខ្ញុំធ្លាប់បានសិក្សា ក្នុងកាលដែលខ្ញុំរៀននៅវិទ្យាល័យព្រះសុរាម្រឹត ប៉ុន្តែញាតិញោមមិនឲ្យខ្ញុំសុខស្រួលបានយូរឡើយ ។ ប្រហែលជាងពីរខែក្រោយមក ពួកគាត់បានចូលមកសុំឲ្យបង្រៀនព្រះអភិធម្ម ។ ពេលនោះ ខ្ញុំហាក់ដូចជាស្រឡាំងកាំង ព្រោះខ្ញុំមិនសូវចេះព្រះអភិធម្មទេ ហើយក៏មិនធ្លាប់បានសិក្សាពីគ្រូណាដែរ ។ ខ្ញុំឆ្លើយប្រាប់ញាតិញោមដោយត្រង់ថា "អាត្មាអត់ចេះទេ ប៉ុន្តែអាត្មានឹងគិតមើលសិន ថាតើអាចទៅរួច ឬមិនរួច ..." ។ កាលនោះខ្ញុំបានទៅភ្នំពេញ ស្វែងរកគម្ពីរដីកាផ្សេង ៗ ដែលទាក់ទងនឹងព្រះអភិធម្ម និងសុំថតចម្លងយកសម្លេងមេរៀនព្រះអភិធម្មអំពីព្រះភិក្ខុធម្មបាល **សុខ រ៉ុប** ដែលបង្រៀនដោយលោកអគ្គបណ្ឌិត **ប៊ុត សាវង្ស** បានចំនួន ២០ កាសែត ។ ខ្ញុំខំស្ដាប់បណ្ដើរ

ស្រាវជ្រាវតាមគម្ពីរដីកាបណ្ដើរ ឃើញថា អ្វីដែលបានស្ដាប់ និង បានស្រាវជ្រាវ សុទ្ធតែជាធម៌អាចយល់ និងបង្រៀនគេបាន ។ ប្រហែលកន្លះខែក្រោយ ខ្ញុំក៏បានបើកបង្រៀនព្រះអភិធម្មថែមទៀត ដោយបង្រៀនមង្គលសូត្រ ២ ថ្ងៃ និងព្រះអភិធម្ម ១ ថ្ងៃ ។

ការដែលខ្ញុំហ៊ានបើកបង្រៀនព្រះអភិធម្ម ទាំងដែលខ្លួនឯងមិនធ្លាប់បានរៀនអំពីសំណាក់គ្រូណានេះ ព្រោះខ្ញុំចងចាំពាក្យសំដីគ្រូរបស់ខ្ញុំដែលលោកមានថេរដីកា ពេលកំពុងបង្រៀនសិស្សថា ...ខ្ញុំព្រះករុណាដែលជាអ្នកបង្ហាត់នេះ គ្រាន់តែជាគ្រូទី ២ ប៉ុណ្ណោះ ឯសៀវភៅទើបជាគ្រូទី ១ .... ។ ដូច្នេះខ្ញុំបានតាំងចិត្តយ៉ាងមុតមាំថា “អញនឹងខំស្ដាប់ និងខំស្រាវជ្រាវដោយខ្លួនឯង ប្រសិនបើមិនយល់ត្រង់ចំណុចណា នឹងទៅសាកសួរលោកអ្នកដែលចេះដឹង” ។ ខ្ញុំចាប់ផ្ដើមបង្រៀនលោកមូលចិត្តជូនទី ១ ទាំងដែលខ្លួនឯងមិនទាន់ចេះលោកមូលចិត្តគ្រប់ទាំង ៨ ដួងផង ប៉ុន្តែចេះតែជាស់តឿនខ្លួនឯងឲ្យមានសេចក្ដីក្លាហានថា “ធ្វើនឹងល្អត្រូវតែសម្រេចកិច្ចការងារមុនទោស់ជានិច្ច” ។ ចាប់ពីពេលនោះមក ខ្ញុំបានប្រគល់ការងារបង្រៀនផ្នែកពុទ្ធិកៈឲ្យព្រះភិក្ខុសុវណ្ណបញ្ញោ **ប៉ុក ស៊ីម** ទាំងស្រុងតែម្ដង ចំណែកខ្ញុំបង្រៀនព្រះធម៌បណ្ដើរ ព្យាយាមសិក្សាស្រាវជ្រាវអភិធម្មបណ្ដើរ ។

ការងាររបស់ខ្ញុំបានប្រព្រឹត្តទៅយ៉ាងរលូន ប៉ុន្តែដើម្បីឲ្យការងារនេះមានវិសាលភាព ខ្ញុំចង់ស្វែងរកទីកន្លែងណាមួយដែលមានទីធ្លាស្រឡះល្អ និងមិនជិតភូមិអ្នកស្រុកពេក ។ គាប់ជួនពេលនោះ លោក **ជុកម៉ិល សន្តិភាព** និងឧបាសិកា **ជា កែវមុនី** មានសេចក្តីជ្រះថ្លា បានប្រគេនដីមួយកន្លែងដែលមានទីតាំងនៅក្នុងភូមិស្ពានថ្ម ឃុំរលាប ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ ។ ខ្ញុំបានធ្វើដំណើរទៅត្រួតពិនិត្យមើល ឃើញថា ទីកន្លែងនោះ មានលក្ខណៈល្អប្រសើរសម្រាប់ពង្រីកការសិក្សា ។

នៅថ្ងៃទី ០១ ខែតុលា ឆ្នាំ ២០០១ ខ្ញុំបានប្រាប់ឲ្យគណៈកម្មការមជ្ឈមណ្ឌលអប់រំពុទ្ធសាសនា វត្តកែវសុវណ្ណ ដែលមានឧបាសិកា **ជា អ៊ុក** ជាប្រធាន ឧបាសិកា **ថៃ សារិន** ជាអនុប្រធាន ធ្វើសំណើសុំច្បាប់ប្តូរទីតាំងមជ្ឈមណ្ឌល ពីវត្តកែវសុវណ្ណ ទៅសាងសង់នៅលើទឹកដីថ្មីដែលទើបទទួលបាន ដោយដាក់ឈ្មោះជាថ្មីថា ពុទ្ធសាសនមណ្ឌលមណីរត្ន ។ ក្រោយមកទៀត សម្តេចព្រះសង្ឃរាជមហាសុមេធាធិបតី បានសុំឲ្យប្តូរឈ្មោះថា **មណ្ឌលសិក្សាព្រះពុទ្ធសាសនាមណីរត្ន** ដូច្នេះវិញ ។

ចំពោះប្រវត្តិនៃការកសាង មណ្ឌលសិក្សាព្រះពុទ្ធសាសនា

មណីរត្ន ខ្ញុំមិនបានរៀបរាប់ក្នុងសៀវភៅនេះទេ បើមានពេលវេលាសមគួរ ខ្ញុំនឹងរៀបរៀងជាសៀវភៅមួយដាច់ដោយឡែកឲ្យបានពិស្តារ ។ ពេលនេះខ្ញុំនិយាយតែចំណុចខ្លះ ៗ ដែលពាក់ព័ន្ធនឹងជីវប្រវត្តិរបស់ខ្ញុំតែប៉ុណ្ណោះ ។

ក្រោយពេលសុំច្បាប់បានហើយ នៅថ្ងៃចន្ទ ៣ កើត ខែអស្សុជ ឆ្នាំម្សាញ់ ព.ស.២៥៤៦ ត្រូវនឹងថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០០១ គណៈកម្មការមណ្ឌល បានចាប់ផ្តើមជីកដីមកចាក់ឲ្យខ្ពស់ឡើង ព្រោះទីកន្លែងថ្មីនេះ អាចត្រូវទឹកជន់លិចនៅរាល់រដូវវស្សា ។

បន្ទាប់ពីចាក់ដីបានទំហំប្រហែល ៥០ ម៉ែត្រ ៤ ជ្រុង គណៈកម្មការបានសាងសង់សាលាបណ្តោះអាសន្នមួយ និងកុដិតូច ៗ ចំនួន ៣ ។

នៅថ្ងៃអង្គារ ១ កើត ខែផល្គុន ឆ្នាំម្សាញ់ ព.ស.២៥៤៦ ត្រូវនឹងថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០០២ ខ្ញុំបានមកស្នាក់នៅក្នុងមណ្ឌលសិក្សាព្រះពុទ្ធសាសនាមណីរត្នរួមជាមួយនឹងភិក្ខុសាមណេរ ៤ រូបទៀត ប៉ុន្តែភិក្ខុសាមណេរ ៤ រូបនោះបានចាកចេញពីមណ្ឌលអស់ទៅហើយ ដោយអង្គខ្លះបានលាចាកសិក្ខាបទ ខ្លះទៀតក៏ទៅបន្តរកចំណេះដឹងផ្សេង ៗ នៅសល់តែខ្ញុំម្នាក់ឯងប៉ុណ្ណោះ រីឯភិក្ខុ

សាមណេរជាង ៤០ រូប ដែលគង់នៅក្នុងមណ្ឌលសព្វថ្ងៃ សុទ្ធតែជាអ្នកមកពេលក្រោយទាំងអស់ ។ ណ្ហើយ! ការជួប គឺជាគូនឹងការព្រាត់អ៊ីចឹងហើយ! អ្នកដែលកំពុងតែជួបគ្នាសព្វថ្ងៃ គង់តែនឹងបែកគ្នាទៀតមិនខាន ។ ដូច្នេះ មុននឹងបែកគ្នា មនុស្សយើង គួរតែធ្វើនូវអំពើល្អដល់គ្នានិងគ្នា ដើម្បីទុកជាការនឹករលឹក ក្រោយពេលដែលបែកគ្នា ។

ក្រោយពីបានមកស្នាក់នៅក្នុងទីលំនៅថ្មី ខ្ញុំបានបន្តការងាររបស់ខ្ញុំ ដូចគ្រាចុងក្រោយនៅវត្តកែវសុវណ្ណជដែល ប៉ុន្តែការងារមានការមមារញឹកជាងមុន ដោយខ្ញុំខំដឹកនាំភិក្ខុសាមណេរក្នុងមណ្ឌលឲ្យសិក្សាព្រះវិន័យ តាមគម្ពីរព្រះត្រៃបិដក ។ ការសិក្សាតាមព្រះត្រៃបិដកនេះមិនមែនអាចយល់ដោយងាយ ៗ ទេ ព្រោះមានកិច្ចនិងពាក្យមួយចំនួនបង្កប់ដោយអត្ថន័យដ៏ជ្រៅ ដូច្នេះត្រូវស្រាវជ្រាវតាមគម្ពីរផ្សេង ៗ ទៀត ដូចជាគម្ពីរព្រះអដ្ឋកថា ដីកា និងយោជនាជាដើម ប៉ុន្តែគម្ពីរទាំងនោះ ខ្មែរយើងមិនទាន់មានទេ មានតែភាសាថៃ ។ ខ្ញុំបានស្វែងរកគ្រូអ្នកបង្រៀនភាសាថៃដោយច្រើនឲ្យមកបង្រៀនអំពីវិធីបកប្រែព្រះធម៌អំពីភាសាថៃដល់ខ្ញុំ និងភិក្ខុសាមណេរក្នុងមណ្ឌល ប៉ុន្តែគ្រូទាំងនោះសុទ្ធតែប្រកែក ព្រោះគេ

មិនចេះភាសាធម៌ទេ ចេះតែភាសាសាមញ្ញធម្មតា ។ កាលបើដូច្នោះ ខ្ញុំក៏រិះគិតសារជាថ្មីថា "កាលនៅភ្នំពេញ អាត្មាអញធ្លាប់រៀនភាសាថៃខ្លះដែរ អញនឹងសាកល្បងប្រែដោយខ្លួនឯង ...." ។ ខ្ញុំបានឲ្យគេទិញវចនានុក្រមថៃ-ខ្មែរបានពីរក្បាល យកមកស្រាវជ្រាវដោយខ្លួនឯងមែន ។

បន្ទាប់ពីបានស្រាវជ្រាវប្រហែលមួយសប្តាហ៍ ឃើញថាខ្ញុំអាចប្រែរួចដោយខ្លួនឯង ព្រោះអត្ថន័យដែលពាក់ព័ន្ធនឹងព្រះធម៌មិនខុសអំពីភាសាបាលីខ្មែរយើងប៉ុន្មានទេ ។ គ្រានោះ ខ្ញុំចាប់ផ្តើមបង្រៀនកិក្ខុសាមណេរក្នុងមណ្ឌល អំពីវិធីបកប្រែភាសាថៃ ។ មិនយូរប៉ុន្មាន កិក្ខុសាមណេរក្នុងមណ្ឌលស្ទើរតែទាំងអស់សុទ្ធតែអាចបកប្រែដោយខ្លួនឯងបានយ៉ាងល្អលើសពីការស្មាន ។

នឹកឡើងគួរឲ្យសប្បាយចិត្តណាស់ ព្រោះអ្វីដែលអ្នកដទៃមិនធ្លាប់ចេះ ខ្ញុំបានធ្វើឲ្យគេចេះ សូម្បីខ្លួនខ្ញុំផ្ទាល់ក៏បានរីកចម្រើនផងដែរ ។

ខ្ញុំធ្លាប់បានផ្តល់ឲ្យអ្នកដទៃ នូវអ្វីដែលគេមិនធ្លាប់មានក្នុងខ្លួនមាន ៣ ចំណុចគឺ :

១. ភាសាបាលី (នេះកាលខ្ញុំចាប់ផ្ដើមបង្រៀននៅវត្ត ពោធិមន្ត្រី ខេត្តតាកែវ និងវត្តពាលញែក ខេត្តពោធិ៍សាត់ ។ ព្រោះតែការចាប់ផ្ដើមនេះ ក្នុងបណ្ដាសិស្សទាំងឡាយរបស់ខ្ញុំ មានសិស្សខ្លះបានវិវឌ្ឍន៍ខ្លួនរបស់គេឲ្យក្លាយជាអ្នកចេះដឹងលើសខ្ញុំទៅទៀត) ។

២. ព្រះអភិធម្ម (ក្នុងបណ្ដាសិស្សរបស់ខ្ញុំភាគច្រើន ចេះព្រះអភិធម្ម ដំណាលគ្នានឹងការបង្រៀនរបស់ខ្ញុំ ប៉ុន្តែខ្លះទៀតធ្លាប់បានចេះពីមុនខ្លះហើយ គ្រាន់តែមករៀនបន្ថែមប៉ុណ្ណោះ) ។

៣. ភាសាថៃ (នៅមណ្ឌលសិក្សាព្រះពុទ្ធសាសនាមណីវត្តគ្រាដំបូង) ។

ការលើកឡើងនេះ លោកអ្នកអាចគិតថា ខ្ញុំអួតអាងអំពីគុណសម្បត្តិខ្លួនឯង ប៉ុន្តែបើទោះជាចូលក្នុងលក្ខណៈនេះខ្លះ ក៏ខ្ញុំត្រូវតែលើកឡើងដែរ ព្រោះគ្មានអ្នកណាដឹងរឿងនេះជាងខ្ញុំឡើយ វៀរលែងតែអ្នកមានគុណធម៌ខ្ពស់ ។ ម្យ៉ាងទៀតដើម្បីញ៉ាំងនូវអបរាបរចេតនាឲ្យចម្រើនឡើង ខ្ញុំត្រូវតែរំលឹកខ្លួនឯងជារឿយ ៗ ធ្វើឲ្យខ្លួនឯងមានសេចក្ដីពេញចិត្ត ក្នុងការបំពេញប្រយោជន៍ដល់សង្គម និងព្រះសាសនាតទៅទៀត ។

# ភាពរីកចម្រើនផ្នែកការសម្ដែងនិងការបង្រៀនព្រះធម៌

ខ្ញុំធ្លាប់ទៅសម្ដែងព្រះធម៌នៅប្រទេសអូស្ត្រាលីចំនួន ៣ ដង គឺ

លើកទី ១ នៅថ្ងៃសៅរ៍ ១ កើត ខែពិសាខ ឆ្នាំច ព.ស.២៥៤៩ ត្រូវនឹងថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០០៦ រយៈពេល ២៨ ថ្ងៃ ។ កាលនោះខ្ញុំបង្រៀនពុទ្ធបរិស័ទ អំពីចិត្តបរមត្ថ ។

លើកទី ២ នៅថ្ងៃ ៣ រោច ខែចេត្រ ចុងឆ្នាំច ដើមឆ្នាំកុរ អដ្ឋស័ក ព.ស.២៥៥០ ត្រូវនឹងថ្ងៃទី ០៥ ខែមេសា ឆ្នាំ ២០០៧ រយៈពេលជាងមួយខែ ។ ក្នុងកាលនោះ ខ្ញុំបានបង្រៀនរូបបរមត្ថ នៅទីក្រុងម៉ែលប៊ន និងកម្មកថានៅទីក្រុងស៊ីដនី ។

លើកទី ៣ នៅថ្ងៃពុធ ០៧ កើត ខែចេត្រ ចុងឆ្នាំជូត ដើមឆ្នាំឆ្លូវ សំរឹទ្ធិស័ក ព.ស.២៥៥២ ត្រូវនឹងថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០០៩ រយៈពេលជាងមួយខែ ។ ក្នុងកាលនោះ ខ្ញុំបានបង្រៀន អំពីអក្ខរវិធី និងសិង្គាលកសូត្រ ។

ក្នុងដំណើរទៅកាន់ប្រទេសអូស្ត្រាលីទាំង ៣ លើក ក្រៅពីការបង្រៀន ខ្ញុំបានទទួលសម្ដែងព្រះធម៌តាមគេហដ្ឋាន ស្ទើរតែរាល់ថ្ងៃ ។

នៅថ្ងៃសុក្រ ០៦ កើត ខែជេស្ឋ ឆ្នាំកុរ ព.ស.២៥៥១ ត្រូវនឹងថ្ងៃទី ០២ ខែមិថុនា ឆ្នាំ ២០០៦ ខ្ញុំបានទៅបើកវគ្គបង្រៀន នៅសាលាសិក្សាព្រះធម៌ព្រះសមណគោតម ស្រុកស្ទោង ខេត្ត កំពង់ធំ ។ វគ្គសិក្សាដំបូងនេះ មានរយៈពេលជាងមួយខែ ដោយ លើកយកព្រះធម្មបទ ៣០ ព្រះគាថាមកបង្រៀន ឲ្យស្របទៅនឹង អាយុរបស់ខ្ញុំ ៣០ ឆ្នាំគត់ ។ ខ្ញុំបានធ្វើកិច្ចការនេះរហូតមិនលះបង់ ដោយក្នុងមួយឆ្នាំទៅបើកវគ្គបង្រៀនពីរដង គឺ ក្រោយចូលឆ្នាំខ្មែរ ជាវគ្គវែង ដែលមានរយៈពេល ពីមួយខែទៅពីរខែ តាមការដែល អាចលៃបាន និងក្នុងព្រះវស្សាមួយសប្តាហ៍ ជួនកាលមុនកាន់បិណ្ឌ ជួនកាលក្រោយភ្ជុំបិណ្ឌ ។ ការងារនេះ ខ្ញុំបានប្រព្រឹត្តធ្វើជាប់ជានិច្ច អស់រយៈពេល ៤ ឆ្នាំហើយ ។

ក្នុងការបង្រៀន ៤ ឆ្នាំកន្លងមក សម្រាប់វគ្គវែងគឺ ឆ្នាំទី ១ បង្រៀនព្រះធម្មបទ ៣០ គាថា ឆ្នាំទី ២ បង្រៀនព្រះធម្មបទ ៣១ គាថា ឆ្នាំទី ៣ បង្រៀនព្រះធម្មបទ ៣២ គាថានិងមេរៀន ព្រះអភិធម្មស្តីអំពីចិត្តបរមត្ថ ឆ្នាំទី ៤ បង្រៀន ព្រះធម្មបទ ៣៣ គាថា និងមេរៀនព្រះអភិធម្មស្តីអំពីចិត្តបរមត្ថ ។ រីឯវគ្គខ្លី ៗ ជួនកាល ខ្ញុំយកព្រះសូត្រផ្សេង ៗ ដូចជាអាឡវកសូត្រជាដើមមកបង្រៀន

ជូនកាលក៏បន្តមេរៀនព្រះអភិធម្ម ។



នៅថ្ងៃទី ១២ ខែសីហា ឆ្នាំ ២០០៧ ខ្ញុំបានទៅបង្រៀនព្រះធម៌ស្តីអំពីអកុសលធម៌ ៩ កង នៅវត្តខេមរែន ក្រុងកំពង់ចាម ខេត្តកំពង់ចាម តាមការស្នើសុំរបស់អតីតព្រះមេគណខេត្ត ព្រះនាម **យ៉ង់ សុខ** និងគណៈកម្មការវត្តខេមរែន ។ វគ្គសិក្សានេះមានរយៈពេល ១១ ថ្ងៃ ។

ក្រោយពេលបញ្ចប់វគ្គសិក្សាដំបូងនេះ គណៈកម្មការវត្តបានរៀបចំសុំច្បាប់បើកវគ្គរៀនសូត្រព្រះធម៌ ហើយសុំឲ្យខ្ញុំទៅបង្រៀនជាទៀងរាល់ឆ្នាំ ។ ខ្ញុំក៏បានទទួលតាមសំណូមពរ ដោយក្នុងមួយឆ្នាំទៅបង្រៀនពីរវគ្គ គឺ វគ្គទី ១ មុនបុណ្យចូលឆ្នាំខ្មែរ និងវគ្គទី ២ មុនពេលចូលព្រះវស្សា ។ ការសិក្សានោះ ដូច្នេះគឺ :

នៅថ្ងៃទី ១២ ខែមេសា ឆ្នាំ ២០០៨ បានទៅបង្រៀនអំពីកម្មកថា រយៈពេល ៤១ ថ្ងៃ ។ រីឯវគ្គបន្តបន្ទាប់មក គឺបង្រៀនមេរៀនព្រះអភិធម្មរហូត ដែលចាប់ផ្តើមអំពីចិត្តបរមត្ថ ។ ខ្ញុំបានប្រព្រឹត្តធ្វើនូវការងារនេះ រហូតមកដល់សព្វថ្ងៃ ។


សាលាសិក្សាព្រះធម៌វត្តខេមរ័ន ក្រុងកំពង់ចាម

# ការងារប្រចាំឆ្នាំ

នៅវត្តមណីរត្ន សង្កាត់រលាប ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ក្នុងមួយឆ្នាំខ្ញុំបើកបង្រៀនព្រះធម៌ ២ លើក គឺ លើកទី ១ នៅខាងក្នុងព្រះវស្សា រយៈពេលពីរខែ និងលើកទី ២ ក្រោយរដូវកឋិន រយៈពេលមួយខែ ។

នៅសាលាសិក្សាព្រះធម៌ព្រះសមណគោតម ស្រុកស្ទោង ខេត្តកំពង់ធំ ក្នុងមួយឆ្នាំខ្ញុំបើកបង្រៀនព្រះធម៌ ២ លើក គឺ លើកទី ១ ក្រោយបុណ្យចូលឆ្នាំខ្មែរ រយៈពេលប្រហែលមួយខែ ឬពីរខែ និងលើកទី ២ មុនបុណ្យកាន់បិណ្ឌ ឬក្រោយភ្ជុំបិណ្ឌ រយៈពេលមួយសប្ដាហ៍ ។

នៅវត្តខេមរ៉ៃន ក្រុងកំពង់ចាម ខេត្តកំពង់ចាម ក្នុងមួយឆ្នាំខ្ញុំបើកបង្រៀន ២ លើក គឺ លើកទី ១ នៅមុនបុណ្យចូលឆ្នាំខ្មែរ រយៈពេលពីមួយខែទៅមួយខែកន្លះ លើកទី ២ មុនពេលចូលព្រះវស្សា រយៈពេលមួយសប្ដាហ៍ ។

គ្រប់ពេលដែលខ្ញុំចេញទៅបំពេញកិច្ចការងារខាងក្រៅ ខ្ញុំបានប្រគល់ការងារក្នុងវត្តឲ្យគ្រូសូត្រស្ដាំ និងគ្រូសូត្រឆ្វេង ជាអ្នកមើលការខុសត្រូវជំនួស ។

# តើសុជាខ្ញុំជាសិស្សរបស់អ្នកណា ?
# អ្នកណាជាគ្រូរបស់ខ្ញុំ ?

ការដែលខ្ញុំលើកឡើងនេះ គឺដើម្បីរំលឹកឡើងវិញនូវគុណូបការៈរបស់គ្រូទាំងឡាយដែលធ្លាប់មានមកលើខ្ញុំ ព្រោះអ្វីគ្រប់យ៉ាងដែលខ្ញុំមានបច្ចុប្បន្ន ភាគច្រើនបានមកដោយសារលោកគ្រូទាំងឡាយនោះឯង ។ ខ្ញុំសូមលើកឡើងត្រឹមពេលចេញបួសប៉ុណ្ណោះ ។

## គ្រូផ្ទាល់

-ព្រះភិក្ខុ **ញ៉ែម វ៉ាន់** ជាព្រះឧបជ្ឈាយ៍របស់ខ្ញុំ ។ លោកមានគុណដូចម្ដាយ ព្រោះបានបង្កើតនូវកំណើតបព្វជិតឲ្យខ្ញុំ និងធ្លាប់ឲ្យឱវាទល្អ ៗ ជាច្រើន ។ លោកបានលាចាកលោកនេះទៅហើយ ។

-ព្រះភិក្ខុ **ឡាយ យ៉ុល** ជាអាចារ្យរបស់ខ្ញុំ ។ លោកមានគុណដូចឪពុក ព្រោះជាអ្នកបង្ហាត់បង្រៀនភាសាបាលីដល់ខ្ញុំ មុនគ្រូណាទាំងអស់ ។ មិនត្រឹមតែប៉ុណ្ណោះ ក្រៅពីការបង្រៀន លោកតែងតែជួយឧបត្ថម្ភខ្ញុំ ទាំងផ្នែកសម្ភារៈ ទាំងផ្នែកស្មារតី ។ លោកតែងណែនាំខ្ញុំឲ្យស្គាល់ខុសត្រូវ ការពារខ្ញុំមិនឲ្យធ្លោយខ្លួនធ្វើអំពើមិនសមរម្យ ។ ខ្ញុំតាំងនៅក្នុងឱវាទរបស់លោក អស់រយៈកាល ៧ ឆ្នាំ ។ សព្វថ្ងៃលោកបានលាចាកសិក្ខាបទទៅហើយ ប៉ុន្តែខ្ញុំនៅតែចាត់ទុកគាត់ថាជាគ្រូទីមួយរបស់ខ្ញុំរហូត ។


ព្រះភិក្ខុ ប៉ុក ជា ឬ ប៉ុក ស៊ឹម
កុដិដែលខ្ញុំស្នាក់នៅវស្សាដំបូង
ព្រះភិក្ខុ ស៊ុន សុផន
ព្រះភិក្ខុ ឡាយ យ៉ុល
នេះជារូបរបស់ខ្ញុំ

-ព្រះភិក្ខុ **កែវ ប្រុស** ជាគ្រូបង្រៀនភាសាបាលី ។ លោកធ្លាប់បង្រៀនខ្ញុំអស់រយៈពេល ៣ ខែ ។

-ព្រះភិក្ខុ **ស៊ុន សុផន** ។ លោកបានរាប់អានខ្ញុំថាជាប្អូន ។ លោកធ្លាប់ជួយបកប្រែគម្ពីរព្រះធម្មបទភាគទី ៤ ដល់ខ្ញុំ ។

-ព្រះភិក្ខុ **ប៉ុក ជា** ។ លោកធ្លាប់បានជួយបកប្រែគម្ពីរធម្មបទភាគទី ២ ដល់ខ្ញុំ ។

-ព្រះភិក្ខុ **នុត សាម៉ុន** ។ លោកធ្លាប់បានបង្រៀនព្រះវិន័យដល់ខ្ញុំអស់រយៈពេលប្រហែលមួយខែ និងធ្លាប់បានបង្ហាញអំពីរបៀបទេសនាខ្លះ ៗ ដល់ខ្ញុំ ។

-លោកគ្រូដ៏ច្រើនរូបនៅវិទ្យាល័យព្រះសុរាម្រឹត ក្រុងភ្នំពេញ មានលោកគ្រូ **រស់ សាវេន** ជាដើម ។ ខ្ញុំធ្លាប់សិក្សានៅទីនោះអស់រយៈពេល ៤ ឆ្នាំ ។ ខ្ញុំមិនចាំឈ្មោះលោកគ្រូទាំងនោះអស់ទេ ។

-ឧបាសិកា **អ៊ឹង គឹមរស់** ។ គាត់ធ្លាប់អញ្ជើញមកបង្រៀនគម្ពីរមហាបដ្ឋានដល់ខ្ញុំ សម្រាប់រយៈពេលខ្លី ។

គ្រូទាំងអស់ដែលខ្ញុំលើកឡើងនេះ ចាត់ជាគ្រូផ្ទាល់ ព្រោះជាអ្នកចំណាយទាំងកម្លាំងកាយ កម្លាំងចិត្ត និងកម្លាំងប្រាជ្ញា ក្នុងការបង្ហាត់បង្រៀនខ្ញុំដោយផ្ទាល់ និងតែងតែខ្វល់ខ្វាយថា ខ្ញុំយល់ ឬមិនយល់ ។ ព្រោះហេតុនោះ ខ្ញុំឲ្យឈ្មោះថា **គ្រូផ្ទាល់** ។

# គ្រូប្រយោល

-លោកតា **ព្រែក តាទែន** (ខ្ញុំមិនស្គាល់ឈ្មោះរបស់លោកពិតប្រាកដទេ) ។ ខ្ញុំធ្លាប់ស្តាប់លោកទេសនាតាមរយៈកាសែត ដែលសម្តែងតាមបុណ្យនានា ប្រហែលពីរ ឬបីកាសែត ហើយខ្ញុំក៏រៀនទេសនាតាមលោក ។

-លោកគ្រូ **កេតុធម្មោ សំ ប៊ុនធឿន** ។ ខ្ញុំព្យាយាមស្តាប់លោកសម្តែងតាមវិទ្យុអស់រយៈកាលដ៏យូរ រហូតកើតសេចក្តីជ្រះថ្លា បានទៅសុំអនុញ្ញាតពីញោមប្រុសស្រី ដើម្បីលះបង់អ្វី ៗ គ្រប់យ៉ាង ចូលទៅធ្វើសមណធម៌ក្នុងព្រៃ ប៉ុន្តែញោមទាំងពីរមិនព្រម ។

-លោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ។ ខ្ញុំព្យាយាមស្តាប់តាមវិទ្យុ និងកាសែតជាច្រើន ។

-លោកគ្រូធម្មាចារ្យ **រស់ សុផាត** ។ ខ្ញុំស្តាប់ការបង្រៀនព្រះអភិធម្មរបស់គាត់តាមកាសែត ។

-លោកគ្រូធម្មាចារ្យ **គាំ អ៊ីវ** ។ ខ្ញុំស្តាប់ការបង្រៀនព្រះវិន័យរបស់គាត់អស់ជាច្រើនកាសែត ។

-លោកយាយ **សុចិន្ត** ជនជាតិថៃ ។ ខ្ញុំបានស្តាប់ការបង្រៀនមេរៀនសតិប្បដ្ឋានរបស់គាត់អស់ជាច្រើនកាសែត ។

-សម្តេចព្រះសង្ឃរាជ **ជោតញ្ញាណោ ជួន ណាត** ។ ខ្ញុំបានស្តាប់ការសម្ភាសន៍អក្សរសាស្ត្ររបស់លោក បានប្រហែល ២០ កាសែត និងបានសិក្សាតាមវចនានុក្រមរបស់លោក មួយអន្លើ ដោយសៀវភៅធម៌ផ្សេង ៗ ដែលលោកបានរៀបរៀង ។

-សម្តេចព្រះសង្ឃរាជ **វជិរប្បញ្ញោ ហួត តាត** ។ ខ្ញុំបានសិក្សាភាសាសំស្ក្រឹត តាមសៀវភៅរបស់លោក និងសៀវភៅ ផ្សេងទៀត ដូចជា ជីវិតមនុស្ស និងមហាវណ្ណកម្មខ្មែរជាដើម ។

-បូរាណបណ្ឌិតខ្មែរជាច្រើន ដែលខ្ញុំមិនបានចាំឈ្មោះអស់ ដូចជា **ព្រះធម្មបាល ខៀវ ជុំ, ព្រះឧត្តមមុនី អ៊ុំ ស៊ូ, ព្រះអាចារ្យ ឈឹម ស៊ុម, ព្រះអាចារ្យ ចាប ពិន, ព្រះអាចារ្យ សូរ ហាយ អ្នកអាចារ្យ អ៊ុច រស់, ព្រះសមុហ៍ លិខិតវង្ស សួង ណែម,** និង**ព្រះគ្រូសិរីសោភ័ណ កិម តូ** ជាដើម ។ ខ្ញុំបានសិក្សាតាមរយៈសៀវភៅជាច្រើន ដែលលោកអ្នកប្រាជ្ញទាំងនេះបានរៀបរៀង ។

បានជាចាត់ទុកលោកទាំងនេះថាជា **គ្រូប្រយោល** ព្រោះខ្ញុំមិនបានទៅរៀនផ្ទាល់អំពីសំណាក់លោកហ្នឹងឯង ។

ខ្ញុំបានបើកបង្ហាញអស់ហើយ លោកអ្នកចាត់ទុកថាខ្ញុំជាមនុស្សបែបណាក៏បាន អាចថា ខ្ញុំជាសិស្សរបស់គ្រូណា ឬថា

អ្នកណាជាគ្រូរបស់ខ្ញុំ ក៏ស្រេចតែការយល់ឃើញទៅចុះ ។ ប៉ុន្តែសម្រាប់ខ្ញុំ អ្នកណាក៏ដោយ ជាអ្នកមានកិត្តិយសក្តិ ឬគ្មានកិត្តិយសក្តិ ឲ្យតែធ្លាប់ផ្តល់នូវចំណេះដឹង និងបទពិសោធន៍ល្អ ៗ ដល់ខ្ញុំ សុទ្ធតែជាគ្រូរបស់ខ្ញុំទាំងអស់ ។

ការរៀបរាប់មកប៉ុណ្ណេះ មិនទាន់ចប់សព្វគ្រប់ទេ ព្រោះសាមីជីវិតមិនទាន់ស្លាប់ ។ បើសាមីជីវិតមិនទាន់ស្លាប់ ជីវប្រវត្តិក៏នៅតែមានជាបន្តទៅទៀត ។ ដូច្នេះជីវប្រវត្តិនេះ ខ្ញុំមិនអាចបញ្ចប់ដោយខ្លួនឯងបានទេ ។ ក្រោយពេលដែលខ្ញុំស្លាប់ហើយ សូមគណៈសិស្សទាំងឡាយជួយបញ្ចប់ឲ្យខ្ញុំផងចុះ ។

# ពុទ្ធភាសិត

**យោ ច បុព្វេ បមជ្ជិត្វា   បច្ឆា សោ នប្បមជ្ជតិ**
**សោ មំ លោកំ បភាសេតិ   អព្ភា មុត្តោវ ចន្ទិមា ៕**

បុគ្គលណាមួយកាលពីមុនប្រមាទហើយ លុះកាលជាខាងក្រោយគេមិនប្រមាទវិញ បុគ្គលនោះ ឈ្មោះថា ញ៉ាំងខន្ធាទិលោកនេះឱ្យភ្លឺច្បាស់ដូចព្រះចន្ទ្ររះផុតចាកពពក ។

**បុគ្គលណា   ធ្លាប់ប្រមាទ   គ្រាកន្លង**
**ធ្លាប់ភ្លាំភ្លង   ប្រព្រឹត្តខុស   ចាកធម្មា**
**លុះពេលក្រោយ   មានស្មារតី   ដឹងអាត្មា**
**មានប្រាជ្ញា   សារត្រឡប់   ប្រព្រឹត្តល្អ ។**
**បុគ្គលនោះ   ពិតល្បីឈ្មោះ   ពីរោះថា**
**ញ៉ាំងលោកា   ឱ្យភ្លឺថ្លា   ថ្លៃបវរ**
**ដូចព្រះចន្ទ   ពេលរាត្រី   រះចេញចរ**
**ពន្លឺល្អ   ផុតស្រឡះ   ចាកពពក ។**

*ដោយភិក្ខុវជិរប្បញ្ញោ សាន សុជា*